00636093

E5

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ~~00២/១៣-0៩-២00៧/អ.វ.ត.ក/អជសជ~~ 002/19-09-2007-អវតក/អជសស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: សម្ងាត់ / Confidential / Confidentiel

ឈ្មោះមន្ត្រីកត់ត្រា: ឡាំ សាមឿន សាធារណៈ / Public

ហត្ថលេខា: __១២_ មករា_២០១១_

---

**បណ្តឹងរបស់លោក អៀង សារី សុំប្តឹងជំទាស់ចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក និងសំណើសុំអោយមានសវនាការជាសាធារណៈ ឬជម្រើសផ្សេងពីនេះអនុញ្ញាតអោយដាក់ចម្លើយតបទៅនឹងអំណះអំណាងនានាដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្តឹងនេះ**

---

**<u>ដាក់ដោយ</u>៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>ផ្ញើជូន</u>៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERNGE

ចៅក្រម យូ ឧត្តរា

ចៅក្រម Claudia FENZ

**<u>ផ្ញើជូន</u>៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារទទួល**

**DOCUMENT RECEIVED/DOCUMENT REÇU**

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 01 / 2011

ម៉ោង (Time/Heure): 11:30

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) ដោយអនុលោមទៅតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងរបស់ អវតក (“វិធាន”) សូមដាក់ពាក្យបណ្ដឹងជំទាស់ចៅក្រម និល ណុន ។ ពាក្យបណ្ដឹងជំទាស់នេះត្រូវធ្វើឡើងជាការចាំបាច់ដោយសារចៅក្រម និល ណុន ត្រូវបានគេយល់ឃើញថាបានឆ្លើយទទួលស្គាល់នៅចំពោះមុខអ្នកថតភាពយន្តឯកសារ Amanda Pike ថា ដោយសាការអនុវត្តជាទម្លាប់ ហើយដែលគាត់យល់ឃើញថាមិនមានអ្វីខុសនោះ គាត់បានទទួលយកសារគុណ (gratuities) ពីភាគីវិវាទដែលបានដឹងគុណគាត់ (ដែលនោះគឺសំណូក) នៅក្នុងរឿងក្ដីដែលគាត់បានទទួលជំនុំជម្រះ ខណៈពេលដែលគាត់មាននាទីជាប្រធានតុលាការនៅខេត្តបាត់ដំបង។ ដោយធ្វើព្រមគ្នាជាមួយនឹង ហើយដែលទាក់ទងនឹងពាក្យបណ្ដឹងជំទាស់នេះ មេធាវីការពារក្ដីបានដាក់សំណើសុំអោយបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបណ្ដឹងរបស់លោក អៀង សារី សុំប្ដឹងជំទាស់ចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក ដោយស្នើសុំ ឬចេញដីកាបង្គាប់អោយអ្នកផលិតភាពយន្ត Amanda Pike អោយលាតត្រដាងបង្ហាញខ្សែភាពយន្តនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតឱ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន (“សំណើសុំស៊ើបអង្កេត”)[1] ដែលក្នុងគោលបំណងដើម្បីទទួលបាននូវខ្សែភាពយន្តពិតប្រាកដ ដែលចៅក្រម និល ណុន ត្រូវបានគេចោទថាបានឆ្លើយទទួលស្គាល់ដែលដាក់បន្ទុកនេះ។ ទាក់ទងនឹងពាក្យបណ្ដឹងជំទាស់នេះ និងសំណើសុំអោយស៊ើបអង្កេតដែលទាក់ទងគ្នានេះ សូមស្នើថា ចៅក្រម និល ណុន គួរតែដកខ្លួនដោយខ្លួនឯងថយចេញពីបញ្ហានានាទាំងអស់ទាក់ទងនឹងសំណុំរឿង ០០២ រហូតដល់មានសេចក្ដីសម្រេចមួយទៅលើបញ្ហានេះត្រូវបានធ្វើឡើងសិន។ សូមស្នើអោយមានសវនាការជាសាធារណៈមួយត្រូវធ្វើឡើង។ បើសិនជាសវនាការមិនត្រូវបានអនុញ្ញាតធ្វើឡើងទេនោះ មេធាវីការពារក្ដីសូមស្នើអោយមានការអនុញ្ញាត អោយដាក់ចម្លើយតបទៅនឹងអំណះអំណាងនានា ដែលបានធ្វើឡើងដោយចៅក្រម និល ណុន នៅក្នុងចម្លើយទៅនឹងពាក្យបណ្ដឹងជំទាស់នេះ។

## I. **បញ្ហាបឋម**

### ក. ភាពអាចទទួលយកបាននៃ និងពេលវេលាសម្រាប់ការដាក់ពាក្យបណ្ដឹងជំទាស់នេះ

---

[1] *រឿងក្ដី* អៀង សារី សំណុំរឿងលេខ ០០២/១៣-០១-២០១១-អវតក/អជសដ សំណើសុំអោយបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបណ្ដឹងរបស់លោក អៀង សារី សុំប្ដឹងជំទាស់ចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក ដោយស្នើសុំ ឬចេញដីកាបង្គាប់អោយអ្នកផលិតភាពយន្ត Amanda Pike អោយលាតត្រដាងបង្ហាញខ្សែភាពយន្តនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតឱ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន ចុះថ្ងៃទី ១៤ មករា ២០១១។

១. វិធាន ៣៤(៤) ចែងថា ពាក្យបណ្ដឹងជិតចិត្តត្រូវតែដាក់ធ្វើប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងណាម្នាក់ <u>នៅពេលសវនាការបឋម</u> ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ។ ប៉ុន្តែ វិធាន ៣៤ ចែងថា ពាក្យបណ្ដឹងជិតចិត្តត្រូវធ្វើឡើង<u>ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ</u>។ ហេតុដូច្នេះ ដើម្បីបំពេញទៅតាមកាតព្វកិច្ចធ្វើកិច្ចការអោយអស់ពីសមត្ថភាព (វីរិយភាព)[2] របស់ខ្លួន មេធាវីការពារក្ដីមិនអាចអង្គុយនៅស្ងៀមយ៉ាងរំភើយ ឬ ដេកចាំទាល់ដល់ពេលសវនាការបឋមទើបរួសរាន់ លើកបញ្ហានេះឡើងមកអង្គជំនុំជម្រះសាលាដំបូងនោះឡើយ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងរួចរាល់ហើយនោះទេ[3]។ សារៈសំខាន់នៃកាតព្វកិច្ចធ្វើសកម្មភាពប្រកបដោយវីរិយភាព នៅក្នុងពាក្យបណ្ដឹងជិតចិត្តចៅក្រម ត្រូវបានពន្យល់សមហេតុសមផលដោយអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (“តុលាការ ICTY”) ក្នុងរឿងក្ដី *Čelebići* ថា៖

> ការខកខានរបស់មេធាវីក្នុងការជំទាស់ ឬ ទាញចំណាប់អារម្មណ៍នៅពេលចៅក្រមកំពុង

---

[2] មេធាវីការពារចុងចោទ ត្រូវតម្រូវអោយធ្វើកិច្ចការដោយមានវីរិយភាពដើម្បីដើម្បីធានាការពារផលប្រយោជន៍របស់កូនក្ដីរបស់ពួកគេ។ វចនានុក្រម *Black's Law Dictionary* បានអោយនិយមន័យ វីរិយភាព ថាជា “ការខិតខំប្រឹងប្រែងអោយអស់ពីសមត្ថភាពសមហេតុផលដែលគេប្រាថ្នាចង់បានពី និងដែលជាធម្មតាប្រើប្រាស់ដោយ បុគ្គលម្នាក់ដែលព្យាយាមបំពេញអោយគ្រប់នូវលក្ខខណ្ឌច្បាប់ ឬដើម្បីបំពេញកាតព្វកិច្ចមួយ” BLACK'S LAW DICTIONARY 468 (7th ed. 1999)។ តុលាការ ICTY បានថ្លែងថា គោលបំណងនៃការបំពេញតម្រូវការនៃសិទ្ធិមួយចំនួនរបស់ជនជាប់ចោទតាមច្បាប់លក្ខន្តិកៈរបស់ តុលាការ ICTY “គឺថាជនជាប់ចោទត្រូវប្រើប្រាស់នូវវីរិយភាពដើម្បីប្រើប្រាស់សិទ្ធិទាំងនោះបាន” ។ អត្ថបទរបស់ចៅក្រម RICHARD MAY និង MARIEKE WIERDA ក្រោមចំណងជើងថា ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអន្តរជាតិ (INTERNATIONAL CRIMINAL EVIDENCE) (Transnational Publishers Inc., 2002) ទំព័រ ៣០៦*ដែលពិភាក្សារឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿង IT-94-1-A សាលដីកាលើពាក្យសុំរបស់ដើមបណ្ដឹងឧទ្ធរណ៍សុំបន្ថែមពេលវេលាកំណត់ និងទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ១៥ តុលា ១៩៩៨។ នៅក្នុងបរិបទនៃពាក្យសុំមួយដើម្បីបើកដំណើរការរឿងក្ដីជាថ្មី អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានថ្លែងថា ការពិចារណាដំបូងរបស់អង្គជំនុំជម្រះ ក្នុងការសម្រេចទៅលើពាក្យសុំអោយបើកដំណើរការរឿងក្ដីជាថ្មី ដើម្បីអនុញ្ញាតអោយទទួលស្គាល់ភស្តុតាងថ្មីចែសគឺជា ចំណោទដែលចោទថាតើ <u>ដោយមានកិច្ចខិតខំប្រឹងប្រែងអស់ពីសមត្ថភាពសមហេតុផល</u> មានភស្តុតាងអាចត្រូវបានគេរកឃើញ និងបង្ហាញនៅក្នុងរឿងក្ដីចម្បងរបស់ភាគីដាក់ពាក្យសុំ។ បើសិនជាអាចរកមិនឃើញទោះបានប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរួចហើយនោះ អង្គជំនុំជម្រះអាចប្រើប្រាស់ឆន្ទានុសិទ្ធិ ទាក់ទងនឹងថា តើត្រូវទទួលយកភស្តុតាងដែរឬទេ។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Delalić et al* សំណុំរឿង IT-96-21-A សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ កុម្ភៈ ២០០១ កថាខណ្ឌ ២៨៣។

[3] *សូមមើល* វិធាន ៦៩, ៧៩ ។

លង់លក់ ឬមិនបង្ហាញការចាប់អារម្មណ៍អំពីដំណើរការនីតិវិធី គឺមានការទាក់ទងដល់បញ្ហាថា តើមានបុរេវិនិច្ឆ័យកើតមានឡើងដែរឬទេ។ ការខកខានរបស់មេធាវីក្នុងការជំទាស់ ជាធម្មតានឹងចង្អុលបង្ហាញថា នៅពេលនោះមេធាវីបានមានទស្សនៈយល់ឃើញថា បញ្ហាចៅក្រមមិនបង្ហាញការចាប់អារម្មណ៍ ដែលធ្វើអោយដំណើរការនីតិវិធីមិនអាចបន្តទៅមុខទៀតបាន ដោយគ្មានការបង្ហាញពីចំណាប់អារម្មណ៍មកលើនោះឡើយ គឺមិនសូវមានសារៈសំខាន់ចំពោះរឿងក្ដីរបស់ពួកគេ[4]។

២. គ្រប់សមាជិកទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ត្រូវតែមានការត្រៀមរៀបចំដូចៗគ្នាសម្រាប់ការចាប់ផ្ដើមនូវការជំនុំជម្រះក្ដីដ៏មានសក្ដានុពលមួយ។ យោងទៅតាមវិធាន ៣៤(១០) បើសិនជាចៅក្រមម្នាក់ត្រូវបានគេដកចេញ ចៅក្រមបំរុងម្នាក់អាចត្រូវបានតែងតាំងជំនួសកន្លែងចៅក្រមម្នាក់នោះ។ ប៉ុន្ដែយោងទៅតាមមាត្រា ១១ថ្មី នៃច្បាប់បង្កើត អវតក ចៅក្រមបំរុងកម្ពុជាទាំងឡាយនៅតែអាចបន្ដបំពេញការងារតាមធម្មតានៅឯតុលាការរបស់ខ្លួន។ ចៅក្រមបំរុងកម្ពុជាទាំងឡាយមិនត្រូវបានគេរំពឹងថានឹងមកបំពេញការងារពេញម៉ោង ដើម្បីត្រៀមរៀបចំការជំនុំជម្រះក្ដីសំណុំរឿង០០២ ដែលអាចនឹងកើតមាន ខណៈដែលខ្លួនត្រូវបំពេញការងារពេញម៉ោងនៅតុលាការធម្មតារបស់ខ្លួនបានឡើយ។ ពេលវេលាសម្រាប់ការត្រៀមរៀបចំ អាចបាត់បង់ប្រសិនពាក្យបណ្ដឹងជិតចិត្ដចៅក្រម និល ណុន មិនត្រូវបានដាក់ធ្វើដោយទាំរហូតដល់សវនាការបឋមនោះ។ ដើម្បីជាប្រយោជន៍យុត្ដិធម៌បញ្ហានេះ *ត្រូវតែ*យកមកដោះស្រាយអោយបានឆាប់រហ័សបំផុត។

៣. ម្យ៉ាងវិញទៀត បញ្ហាអញ្ញត្រកម្មនានាដែលនឹងកើតមានឡើងនាពេលសវនាការបឋម និងនាពេលជំនុំជម្រះក្ដី មានសារៈសំខាន់បំផុត ដោយសារវានឹងមានការពាក់ព័ន្ធដល់បញ្ហាអញ្ញត្រកម្មដែលទាក់

---

[4] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Delalić *et al* សំណុំរឿង IT-96-21-A សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ កុម្ភៈ ២០០១ កថាខណ្ឌ ៦៣១។ សូមមើលផងដែរ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Karemera សំណុំរឿង ICTR-98-44-AR15*bis*.2 សំអាងហេតុសម្រាប់សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំ (interlocutory appeal) ទាក់ទងនឹងការបន្ដនីតិវិធីដោយមានចៅក្រមជំនួស និងលើពាក្យសុំរបស់ Nzirorera សុំអនុញ្ញាតអោយពិចារណាភស្ដុតាងថ្មី ចុះថ្ងៃទី ២២ តុលា ២០០៤។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Sesay *et al* សំណុំរឿង SCSL-2004-AR15-15 សាលដីកាលើពាក្យសុំរបស់មេធាវីការពារក្ដីសុំប្ដឹងជិតចិត្ដចៅក្រម Robinson ចេញពីអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ មីនា ២០០៤។ នៅក្នុងរឿងក្ដី ទាំងនេះ បើសិនជាមេធាវីការពារក្ដីមិនបានធ្វើកិច្ចការប្រកបដោយវីរិយភាព នោះចៅក្រមដែលគេប្ដឹង ដែលចុងក្រោយត្រូវបានគេរកឃើញថា មិនពេញលក្ខណៈដើម្បីកាត់សេចក្ដីនៅក្នុងរឿងក្ដី ដោយសារភាពលំអៀង ឬ ភាពលំអៀងដែលស្ដែងចេញមកក្រៅ នឹងនៅតែបន្ដកាត់ក្ដីលើរឿងក្ដីនោះដដែល ដែលធ្វើខូចខាតដល់សិទ្ធិរបស់កូនក្ដីរបស់ពួកគេ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្ដិធម៌។

00636097



ទងនឹងយុត្តាធិការរបស់ អវតក ដើម្បីកាត់សេចក្តីលោក អៀង សារី[5]។ បញ្ហាទាំងនេះមិនអាចបណ្តោយទុកអោយចៅក្រមម្នាក់ ធ្វើការសម្រេចសេចក្តីដែលចៅក្រមនេះអាចមិនមានអនាគតិ និងឯករាជ្យភាពបានឡើយ។ សិទ្ធិទាំងឡាយរបស់លោក អៀង សារី មិនអាចទទួលបានការការពារគ្រប់គ្រាន់ លុះត្រាតែមេធាវីការពារក្តីដាក់ពាក្យបណ្តឹងជិតចិត្តនេះក្នុងពេលវេលាដ៏ឆាប់បំផុតតាមដែលអាចធ្វើបាន។ វិធាន ៣៤(៩) ចែងថា "កិច្ចដែលបានបំពេញដោយចៅក្រមដែលត្រូវគេប្តឹងជិតចិត្ត មុនពេលមានសេចក្តីសម្រេចលើពាក្យបណ្តឹងជិតចិត្តនោះត្រូវចាត់ទុកថាមានសុពលភាព"។

**ខ. សូមស្នើថា ចៅក្រម និល ណុន សុំដកខ្លួនចេញដោយខ្លួនឯងចេញពីការសម្រេចលើពាក្យបណ្តឹងជិតចិត្តនេះ និងចេញពីបញ្ហានានាដែលរង់ចាំការសម្រេចនៅមុនពេលមានសេចក្តីសម្រេចលើពាក្យបណ្តឹងជិតចិត្តនេះត្រូវបានគេធ្វើឡើង**

៤. វិធាន ៣៤ មិនតម្រូវអោយចៅក្រមម្នាក់ ដែលកំពុងត្រូវបានគេប្តឹងជិតចិត្ត ដកខ្លួនឯងចេញខណៈពេលដែលពាក្យបណ្តឹងជិតចិត្តនេះរង់ចាំការសម្រេចនោះទេ។ "ប៉ុន្តែចៅក្រមនោះ អាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន នៅគ្រប់ពេលវេលាក្នុងដំណើរការនីតិវិធី"[6]។ វានឹងជាការរំលោភលើក្រមសីលធម៌ចៅក្រមរបស់ អវតក សម្រាប់ចៅក្រមម្នាក់ដែលសម្រេចលើបញ្ហានៃការប្តឹងជិតចិត្តខ្លួន។ មាត្រា ២(២) នៃ ក្រមសីលធម៌ចៅក្រមរបស់ អវតក តម្រូវថា "ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬ ស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានជម្លោះផលប្រយោជន៍កើតឡើង"។ ហេតុដូច្នេះ ចៅក្រម និល ណុន *ត្រូវតែ*ដកខ្លួនឯងចេញពីការសម្រេចទៅលើបញ្ហានេះ។ រឿងនេះនឹងស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តដែលបានធ្វើពីមុនរួចមកហើយនៅចំពោះមុខ អវតក[7] ។ លើសពីនេះទៀត រហូតទល់តែដល់ពេលពាក្យបណ្តឹងជិតចិត្តនេះត្រូវបាន

---

[5] វិធាន ៨៩ អនុញ្ញាតអោយភាគីនានាដាក់បណ្តឹងអញ្ញត្រកម្មអំពីបញ្ហាយុត្តាធិការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃដីកាដំណោះស្រាយចូលស្តាពរ។

[6] វិធាន ៣៤(៥)។

[7] *សូមមើលរឿងក្តី* នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី ៤ កុម្ភៈ ២០០៨ ឯកសារលេខ C11/29, ERN 00160734-00160742 ("សាលដីកាបណ្តឹងជិតចិត្ត ន័យ ថុល") ។ *សូមមើលរឿងក្តី* អៀង សារី សំណុំរឿងលេខ ០០២/២០-១០-២០០៩-អវតក/អបជ(០៣) ចម្លើយតបទៅនឹងសំណើសុំរបស់ អៀង សារី ស្នើសុំនូវចំណាត់ការសមរម្យ ទាក់ទិនទៅនឹងសេចក្តីថ្លែងការណ៍មួយចំនួនរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាព

សម្រេចពេញលេញហើយ ចៅក្រម និល ណុន *ដាច់ខាត*មិនត្រូវចូលរួមនៅក្នុងបញ្ហានានាដែលកំពុងរង់ចាំការសម្រេច ឬ បំពេញសកម្មភាពណាមួយនៅក្នុងការត្រៀមរៀបចំសំណុំរឿង ០០២ ឡើយ ធ្វើដូច្នេះដើម្បីកុំអោយមានការជាប់ប្រឡាក់ប្រឡូស បើសិនជាចៅក្រម និល ណុន ត្រូវបានគេដកគុណវុឌ្ឍិនៅពេលក្រោយមកនោះ។

**គ. សូមស្នើអោយមានសវនាការជាសាធារណ: ឬ ជម្រើសផ្សេងពីនេះ អនុញ្ញាតអោយដាក់ចម្លើយតបទៅនឹងអំណះអំណាងនានាដែលដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្ដឹងជិតចិត្តនេះ**

៥. សវនាការជាសាធារណ:គឺចាំបាច់។ ពាក្យបណ្ដឹងជិតចិត្តពាក់ព័ន្ធនឹងសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលត្រូវទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងឥតលំអៀង។ មិនមានហេតុផលដែលអាចធ្វើយុត្តិកម្មចំពោះថា ហេតុអ្វីបានជា ពាក្យបណ្ដឹងជិតចិត្តនេះមិនគួរយកមកពិភាក្សា និងជជែកដេញដោលប្រកបដោយតម្លាភាព និងដោយមានវត្តមានសាធារណ:ជននោះឡើយ។ ប្រជាជនកម្ពុជា ដោយខ្លួនទទួលអត្ថប្រយោជន៍មកជាមួយស្រាប់ពីការទទួលបានចៅក្រម អវតក ដែលមានភាពឯករាជ្យ និងឥតលំអៀង គឺមានសិទ្ធិពិនិត្យពិច័យលើដំណើរការនីតិវិធីទាំងនេះ[8]។ កង្វះតម្លាភាព និងទំនួលខុសត្រូវនៅ អង្គការសហប្រជាជាតិ បានជះឥទ្ធិពលដល់ទំនុកចិត្តកាលពីអតីតកាល ហើយគេបានចាត់វិធានការ

របស់ចៅក្រមអង្គបុរេជំនុំជម្រះចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing ចុះថ្ងៃទី ១ វិច្ឆិកា ២០០៩ ឯកសារលេខ 3, ERN: 00398615-00398622 កថាខណ្ឌ ២។

[8] ដូចដែលអង្គបុរេជំនុំជម្រះកាលពីមុនបានទទួលស្គាល់ថា "មូលដ្ឋានចំបងមួយក្នុងចំណោមមូលដ្ឋាននានាសម្រាប់ការបើកសវនាការជាសាធារណ: គឺដើម្បីអោយសាធារណជនអាចពិនិត្យពិច័យលើភាពត្រឹមត្រូវយុត្តិធម៌នៃដំណើរការនីតិវិធី"។ *រឿងក្តី* ខៀវ សំផន សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១១) សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបើកសវនាការសាធារណ: ចុះថ្ងៃទី ៤ វិច្ឆិកា ២០០៨ ឯកសារលេខ A190/I/8, ERN: 00236251-00236254 ។ ដូចដែលបានកត់សម្គាល់ដោយអង្គការគំនិតផ្តួចផ្តើមសង្គមសេរី (Open Society Justice Initiative) "ដោយអវត្តមាននៃការចង្អុលបង្ហាញពីភាពចាំបាច់ខ្លាំងក្លាសម្រាប់ភាពសម្ងាត់ក្នុងបញ្ហាសំខាន់មួយ គេគួរយកវិធានដែលអំណោយផលដល់តម្លាភាពមកអនុវត្តដើម្បីអនុញ្ញាតអោយសាធារណ:ជនអាចសង្កេតមើលលើកិច្ចការរបស់តុលាការ"។ *របាយការណ៍ស្តីពី ការជ្រៀតជ្រែកខាងនយោបាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (*Political Interference in the Extraordinary Chambers in the Courts of Cambodia*) របស់អង្គការ OPEN SOCIETY JUSTICE INITIATIVE ចេញផ្សាយខែ មិថុនា ២០១០ ទំព័រ ២៧ ("របាយការណ៍របស់ OSJI")។

ជាច្រើនដើម្បីធ្វើអោយប្រសើរឡើងនូវស្ថានភាពនេះ[9]។ អវតក គួរប្រកាន់យកនូវជំហរស្រដៀងគ្នានេះ ដើម្បីធានាថា ដំណើរការនីតិវិធីមានតម្លាភាព ហើយអ្នកធ្វើសេចក្តីសម្រេចមានទំនួលខុសត្រូវ។

៦. ជម្រើសផ្សេងពីនេះ បើសិនជាសវនាការជាសាធារណៈមិនត្រូវបានអនុញ្ញាត មេធាវីការពារក្តីសូមស្នើអោយអនុញ្ញាតអោយខ្លួនដាក់ចម្លើយតប ទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សរនានា ដែលដាក់ដោយចៅក្រម និល ណុន អនុលោមទៅតាមវិធាន ៣៤(៧) ។ ខណៈពេលដែលវិធានផ្ទៃក្នុងមិនមានចែងអំពីករណីថា តើមេធាវីការពារក្តី អាចដាក់ចម្លើយតបនៅក្នុងករណីបែបនេះដែរឬទេនោះ ចម្លើយតបនានាជាច្រើនត្រូវបានអនុញ្ញាតអោយដាក់ធ្វើ នៅពេលដែលសវនាការមិនត្រូវបានអនុញ្ញាតធ្វើឡើង[10]។

## II. សាវតា

៧. ក្នុងឆ្នាំ ២០០២ អ្នកថតភាពយន្តឯកសារ Amanda Pike បានធ្វើដំណើរមកដល់កម្ពុជាក្នុងគម្រោងការយកព័ត៌មានអន្តរជាតិ (International Reporting Project Fellowship) ដែលទទួលបានមកពីសកលវិទ្យាល័យ Johns Hopkins (Paul H. Nitze School of Advanced

---

[9] *សូមមើល* អត្ថបទរបស់ Neil Macfarquhar ក្រោមចំណងជើងថា *អង្គការសហប្រជាជាតិយល់ព្រមលើការតែងតាំងប្រធានអង្គភាពប្រឆាំងអំពើពុករលួយថ្មី* (*UN Approves New Anti-Corruption Chief*) បោះពុម្ពផ្សាយដោយ INTERNATIONAL HERALD TRIBUNE ចុះថ្ងៃទី ៣០ កក្កដា ២០១០ ទំព័រ ៣ ដែលលោកស្រី Inga-Britt Ahlenius ដែលជានាយករបស់ការិយាល័យសេវាកម្មស៊ើបអង្កេតផ្ទៃក្នុងដែលត្រូវចាកចេញនោះ (Office of Internal Oversight Services) ត្រូវបានគេរាយការណ៍ថា បានថ្លែងនៅក្នុងរបាយការណ៍បញ្ចប់ភារកិច្ចផ្ទៃក្នុងរបស់គាត់ថា នៅអង្គការសហប្រជាជាតិ (យ៉ាងហោចណាស់ទាក់ទងនឹងការបើកកកាយអំពើពុករលួយផ្នែកហិរញ្ញវត្ថុ) "*វាមិនមិនមានតម្លាភាព។ មានកង្វះខាតខាងទំនួលខុសត្រូវ*" ។

[10] មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅចំពោះមុខ អវតក ចែងថា "សំណើឆ្លើយតបចំពោះសារណាតបនឹងត្រូវអនុញ្ញាត នៅក្នុងករណីតែមិនមានការស្នើសុំអោយមានការជេញដោលផ្ទាល់មាត់ ហើយការឆ្លើយតបនោះ ត្រូវដាក់ក្នុងរយៈពេល០៥ (ប្រាំ) ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងជាភាសាដែលភាគីបានស្នើសុំនោះ ដែលបានចែងនៅក្នុងមាត្រា ២.២ អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយតប។" សំណើឆ្លើយតប (ចម្លើយតប) ត្រូវបានទទួលយកជាច្រើនដងរួចមកហើយកាលពីអតីតកាល *សូមមើល ឧទាហរណ៍ដូចជា សូមមើលរឿងក្តី* អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៩) ចម្លើយតបរបស់ អៀង សារី ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ កសចស ទៅលើសំណើរបស់ អៀង សារី ទាក់ទងនឹងការទទួលយក និងការពឹងផ្អែកទៅលើភស្តុតាងដែលទទួលបានដោយសារអំពើទារុណកម្ម ចុះថ្ងៃទី ១៤ ធ្នូ ២០០៩ ឯកសារលេខ D130/7/3/4, ERN: 00414501-00414508។

00636100



International Studies of Johns Hopkins University)[11] ហើយបានផលិតភាពយន្តឯកសារមួយក្រោមចំណងជើងថា "កម្ពុជា៖ ស្រមោលរបស់ ប៉ុល ពត" (Cambodia: Pol Pot's Shadow)[12]។

៨. ខណៈពេលថតខ្សែភាពយន្តឯកសារនេះ អ្នកនាង Pike ក៏បានធ្វើការស្រាវជ្រាវផ្សេងទៀត ដែលក្រោយមកបង្កើតបានជា អត្ថបទសរសេរជាច្រើនដែលជាផ្នែកមួយនៃទិន្នានុលេខ (Dirary) ជាបន្តបន្ទាប់ ហើយបានដាក់បង្ហោះផ្សាយលើគេហទំព័ររបស់ Frontline/World ដែលគេនៅតែអាចរកឃើញអត្ថបទទាំងនេះរហូតដល់សព្វថ្ងៃនេះ[13]។ ក្នុងចំណោមអ្នកដែលត្រូវបានអ្នកនាង Pike បានសម្ភាសន៍មានចៅក្រម និល ណុន ដែលកាលនោះជាប្រធានតុលាការខេត្តបាត់ដំបង។ ការសម្ភាសន៍នេះបានក្លាយជាអត្ថបទសរសេររបស់គាត់ដែលមានចំណងជើងថា "ខេត្តបាត់ដំបង៖ ចៅក្រម" (Battambang: The Judge)។ នៅក្នុងអត្ថបទសរសេរនេះ អ្នកនាង Pike បានរាយការណ៍ថា៖

> យើងជជែកជាមួយចៅក្រម និល ដែលគាត់និយាយថា គាត់ពិបាកចិត្តដោយសារប្រជាជនខ្វះជំនឿជឿជាក់នៅក្នុងប្រព័ន្ធយុត្តិធម៌។ គាត់បានត្អូញត្អែរថា គាត់ជាញឹកញាប់ត្រូវតែការពារវិជ្ជាជីវៈ និងមិត្តភក្តិរបស់គាត់។ ក្រៅពីនោះ គាត់ទទួលបានប្រាក់ខែត្រឹមតែ ៣០ដុល្លាប៉ុណ្ណោះក្នុងមួយខែ ដែលស្ទើតែមិនគ្រាន់សម្រាប់ចិញ្ចឹមគ្រួសាររបស់គាត់។ គាត់សួរដោយញញឹមចេញធ្មេញថា តើមានអ្វីទៀតដែលគាត់គួរធ្វើនោះ?[14]

៩. ក្នុងខែ មិថុនា ២០០៦ ចៅក្រម និល ណុន ត្រូវបានគេរាយការណ៍ថាបានបដិសេធថា គាត់មិនដែលបាននិយាយទទួលស្គាល់បែបនេះទេ ឬធ្លាប់ចូលរួមការសម្ភាសន៍បែបនេះជាមួយអ្នកនាង Pike

---

[11] *សូមមើល* គេហទំព័រ http://www.internationalreportingproject.org/stories/detail/665/.។

[12] *សូមមើល* គេហទំព័រ http://www.pbs.org/frontlineworld/stories/cambodia/.។

[13] *សូមមើល* គេហទំព័រ http://www.pbs.org/frontlineworld/stories/cambodia/diary01a.html.។

[14] *សូមមើល* Amanda Pike *កម្ពុជា៖ស្រមោលរបស់ប៉ុលពត (Cambodia: Pol Pot's Shadow)* FRONTLINE/WORLD ខែតុលា ២០០២ *ដែលអាចរកបាននៅគេហទំព័រ* http://www.pbs.org/frontlineworld/stories/cambodia/diary04.html (គូសបញ្ជាក់បន្ថែម)។

ឡើយ[15]។ នាចុងខែដដែលនោះ ចៅក្រម និល ណុន ត្រូវបានអ្នកយកព័ត៌មានរបស់កាសែត ឌឹខេមបូឌៀដេលី (The Cambodia Daily) គឺ James Welsh (ដែលសព្វថ្ងៃគឺជាពណ្ណាធិការ ឬអ្នកចាត់ចែងបោះពុម្ពផ្សាយ (Managing Editor)) និង Prak Chan Tul បានទំនាក់ទំនងមក ចៅក្រម និល ណុន ដើម្បីមានមតិអំពីអ្វីដែលបានរាយការណ៍ដោយអ្នកនាង Pike ឧទាហរណ៍ដូច ជាថា ចៅក្រម និល ណុន បានទទួលស្គាល់ការទទួលយកប្រាក់កាសពីភាគីវិវាទដែលពេញចិត្ត ពេញថ្លើមនឹងសេចក្តីសម្រេចរបស់គាត់។ ចៅក្រម និល ណុន បានឆ្លើយតប បើតាមអត្ថបទ សរសេររបស់កាសែត ឌឹខេមបូឌៀដេលី ដែលមានចំណងជើងថា "អ្នកផលិតខ្សែថតភាពយន្តបាន អោយដឹងថា ចៅក្រមនៅ អវតក បានទទួលយកប្រាក់ពីប្រជាជន" ចុះផ្សាយថ្ងៃទី ១០ និង ១១ មិថុនា ២០០៦ ថា "ខ្ញុំមិនដឹង។ ខ្ញុំមិនផ្តល់ព័ត៌អ្វីទេ"។ អត្ថបទសរសេរនេះបាននិយាយបន្ថែមថា ៖

> អ្នកនាង Amanda Pike អ្នកផលិតខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "កម្ពុជា: ស្រមោលរបស់ប៉ុលពត" បានសរសេរក្នុងសារអេឡិចត្រូនិចមួយដែលបាន ទទួលកាលពីថ្ងៃសុក្រថា នាងបានពិនិត្យឡើងវិញយ៉ាងយកចិត្តទុកដាក់នូវខ្សែអាត់សម្លេង និងអត្ថបទចម្លងជាលាយល័ក្ខណអក្សរអំពីបទសម្ភាសន៍ជាមួយលោក និល ណុន។
>
> អ្នកនាងបានបន្ថែមទៀតថា៖ "យើងបានសម្ភាសន៍ចៅក្រម និល ណុន ដោយមានការថត រូបភាពវីដេអូ អស់រយៈពេល១ម៉ោង និង៤៥នាទី កាលពីថ្ងៃទី២១ ខែមិនា ឆ្នាំ២០០២ នៅក្នុងទីក្រុងភ្នំពេញ។ យើងបានថតជាខ្សែភាពយន្តនូវនីតិវិធីក្នុងបន្ទប់តុលាការខេត្ត បាត់ដំបងរបស់គាត់នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២"។
>
> អ្នកនាងPike បានឲ្យដឹងទៀតថា៖ "យើងក៏មានលិខិតអនុញ្ញាតឲ្យចាក់ផ្សាយដែលមាន ហត្ថលេខារបស់លោក និល ណុន ផងដែរដែលក្នុងនោះលោក និល ណុន យល់ព្រមឲ្យ យើងថតទុកជាខ្សែភាពយន្តឯកសាររបស់យើង"។
>
> **Pike បានបន្តទៀតថា ក្នុងអំឡុងបទសម្ភាសន៍នោះ អ្នកនាងបានសួរ លោក និល ណុន ថាតើប្រជាជន ធ្លាប់បានឲ្យប្រាក់គាត់ដើម្បីឲ្យគាត់ប្រឹងប្រែងធ្វើឲ្យពួកគេឈ្នះក្តីដែរឬ ទេ[sic]។**
>
> **"លោក និល ណុន ឆ្លើយថា បាទធ្លាប់។ ករណីនេះ វាកើតឡើងចំពោះរូបខ្ញុំក៏ដូចជាអ្នក ដទៃដែរ ប៉ុន្តែវាមិនមែនតាមរយៈការខិតខំប្រឹងប្រែងខាងខ្ញុំទេ។ ប៉ុន្តែប្រសិនបើបន្ទាប់ពីការ**

---

[15] អត្ថបទសរសេររបស់ James Welsh & Prak Chan Thul ក្រោមចំណងជើងថា *អ្នកផលិតខ្សែភាពយន្តបានឲ្យដឹងថា ចៅក្រមនៅ អវតក បានទទួលប្រាក់ពីប្រជាជន* CAMBODIA DAILY ១០-១១ មិថុនា ២០០៦។ ការបកប្រែជាភាសាខ្មែរក៏អាចរក បាននៅបញ្ជីឯកសារយោងសំអាងផ្លូវច្បាប់ (Table of Authorities)។

ជំនុំជ្រះក្តីរួច ប្រជាជនគេដឹងគុណខ្ញុំហើយពួកគេឱ្យខ្ញុំនូវអ្វីមួយវាការតបស្នងនោះ វាជារឿងធម្មតាទេ។ ខ្ញុំមិនបដិសេធឡើយ”។

Pike បានអះអាងថា លោក និល ណុន បានបន្ថែមទៀតថា៖“ខ្ញុំបានដោះស្រាយរឿងក្តីឱ្យពួកគេ ហើយប្រជាជនគេដឹងគុណខ្ញុំ។ស្ថានភាពរស់នៅបច្ចុប្បន្ននេះមានការលំបាកសម្រាប់រូបខ្ញុំ។ ប៉ុន្តែបើអ្នកនិយាយអំពីការដាក់សំពាធលើប្រជាជនដើម្បីទទួលបានប្រាក់សំណូកវិញនោះ គឺគ្មានទេ” [16]។

១០. ដោយបានដឹងពីអត្ថបទសរសេរនេះ មេធាវីការពារក្តីបានចាត់វិធានការដើម្បីស្វែងរកអ្នកនាង Pike និងដើម្បីទទួលបាននូវខ្សែវីដេអូនៃការសម្ភាសន៍របស់អ្នកនាង Pike ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតថត និងចាក់ផ្សាយរបស់ចៅក្រម និល ណុន[17]។ នៅថ្ងៃទី ៨ កញ្ញា ២០១០ អ្នកនាង Pike បានឆ្លើយតបតាមរយៈសារអ៊ីមែល កត់សម្គាល់ថាខ្លួនអ្នកនាង និងដៃគូរផលិតខ្សែភាពយន្តម្នាក់ទៀតលោក Adam Keker គឺជាម្ចាស់កម្មសិទ្ធិនៃសម្ភារៈវត្ថុដែលបានស្នើសុំ ហើយដោយសារ “ហេតុផលវិជ្ជាជីវៈសារព័ត៌មាន” ពួកគាត់មិនអាចផ្តល់ជូនដោយ "ស្ម័គ្រចិត្ត" នូវសម្ភារៈវត្ថុដែលបានស្នើសុំឡើយ ហើយការទំនាក់ទំនងផ្សេងៗនាអនាគតអំពីបញ្ហានេះ គួរត្រូវទំនាក់ទំនងទៅកាន់មេធាវីរបស់ពួកគេ John Keker មានការិយាល័យមេធាវី Keker & Van Nest អាស័យដ្ឋានផ្ទះលេខ 710 ផ្លូវ Sansome, San Francisco, CA 94111,USA, (415) 391-5400[18]។

១១. នៅថ្ងៃទី ៩ កញ្ញា ២០១០ មេធាវីការពារក្តីបានប្រគល់លិខិតដោយផ្ទាល់ដៃទៅអ្នកចាត់ចែងបោះពុម្ពផ្សាយលោក Welsh នៅស្នាក់ការកាសែតឌីខេមបូឌៀដេលី[19]។ តាមរយៈលិខិតនេះ មេធាវីការពារក្តីបានស្នើសុំសំណៅចម្លងនៃសារអ៊ីមែលឆ្លងឆ្លើយរវាងអ្នកនាង Pike និងកាសែត ឌីខេមបូឌៀ-ដេលី ទាក់ទងនឹងការសម្ភាសន៍ជាមួយចៅក្រម និល ណុន ។ កាលពីថ្ងៃទី ១៦ កញ្ញា ២០១០ មេធាវីការពារក្តីបានទទួលលិខិតដែលផ្ញើរតាមសារអ៊ីមែល ពីលោក Welsh ដែលក្នុងនោះគាត់បានថ្លែងថា កាតព្វកិច្ចវិជ្ជាជីវៈ និងក្រមសីលធម៌របស់គាត់ បានរារាំងគាត់មិនអោយផ្តល់ដល់

---

[16] *ដូចយោងខាងលើ*។(គូសបញ្ជាក់បន្ថែម)។

[17] *សូមមើល* សាអ៊ីមែលពី Michael G. Karnavas ផ្ញើរទៅកាន់អ្នកនាង Pike ឧបសម្ព័ន្ធ ក ។

[18] *សូមមើល* ឧបសម្ព័ន្ធ ខ។

[19] *សូមមើល* ឧបសម្ព័ន្ធ គ។

មេធាវីការពារក្ដី នូវសំណៅចម្លងនៃសារអ៊ីមែលឆ្លងឆ្លើយរបស់គាត់បានឡើយ[20]។

១២. កាលពីថ្ងៃទី ១៧ កញ្ញា ២០១០ មេធាវីការពារក្ដីបានដាក់បណ្ដឹងជិតចិត្តចៅក្រម និល ណុន និងសំណើសុំទាក់ទាក់គ្នាមួយទៀតសម្រាប់ការបំពេញកិច្ចស៊ើបសួរ ទៅអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែត្រូវបានជូនដំណឹងថា អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានទទួលសំណុំរឿងនៅឡើយ ហើយមិនអាចទទួលយកការដាក់ឯកសារទាំងនេះបានឡើយ[21]។

១៣. កាលពីថ្ងៃទី ១៣ មករា ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងរួចហើយ។ ឥឡូវនេះមេធាវីការពារក្ដីសូមដាក់នូវពាក្យបណ្ដឹងទាំងនេះ[22]។

## III. ច្បាប់ដែលត្រូវយកមកអនុវត្ត

### ក. លក្ខខណ្ឌតម្រូវនៃតុលាការដែលឯករាជ្យ អនាគតិ និង មិនពុករលួយ

១៤. អនុលោមទៅតាមមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា "អំណាចតុលាការជាអំណាចឯករាជ្យ ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ"[23] ។ម្យ៉ាងទៀត អនុលោមទៅតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិ កុមារ" ។

១៥. អនុលោមតាមមាត្រា ៣(៣) នៃកិច្ចព្រមព្រៀង ចៅក្រម "ត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត" ហើយចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន ហើយមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ" ។

---

[20] *សូមមើល* ឧបសម្ព័ន្ធ ឃ។

[21] *សូមមើល* ឧបសម្ព័ន្ធ ង ដែលជាអនុស្សារណៈមួយចុះថ្ងៃទី ២៣ កញ្ញា ២០១០ មកពីអង្គបុរេជំនុំជម្រះ ផ្ញើរទៅកាន់អង្គជំនុំជម្រះសាលាដំបូង និង អនុស្សារណៈមួយចុះថ្ងៃទី ២៤ កញ្ញា ២០១០ មកពីអង្គជំនុំជម្រះសាលាដំបូង ផ្ញើរទៅកាន់មេធាវីការពារក្ដីទាក់ទងនឹងការដាក់ពាក្យបណ្ដឹងទាំងនេះ។

[22] *សូមមើល រឿងក្ដី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ មករា ២០១១ ឯកសារលេខ D427/1/26, ERN: 00634887-00634891 ។ *សូមមើលផងដែរ* វិធាន ៦៩, ៧៩។

[23] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ ។

១៦. អនុលោមតាមមាត្រា ១០ថ្មី នៃច្បាប់បង្កើត អវតក មានការប្រើពាក្យស្រដៀងគ្នាសឹងតែទាំងអស់ ចៅក្រម "ត្រូវមានចរិតលក្ខណៈ [និង] ស្មារតីខ្ពស់ មិនលំអៀង និងសុចរិត..." ហើយចៅក្រមត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ" ។

១៧. អនុលោមតាមមាត្រា ១ នៃបទប្បញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ("ក្រមព្រហ្មទណ្ឌអ៊ុនតាក់")៖

**មាត្រា ១៖ ឯករាជ្យភាពនៃចៅក្រម**

១. ឯករាជ្យភាពនៃចៅក្រមត្រូវតែធានាឱ្យមានលក្ខណៈស្របនឹង*គោលការណ៍មូលដ្ឋានស្ដីពីឯករាជ្យភាពនៃចៅក្រម* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។ ចៅក្រមទាំងឡាយត្រូវកាត់ក្តីតាមភាពមិនលម្អៀង ផ្អែកលើហេតុការណ៍ដែលមាននៅចំពោះមុខ ហើយក្នុងការគោរពច្បាប់ ដោយមិនព្រមទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យដោយចំពោះ ឬដោយមិនចំពោះ អំពីភាគីណាមួយក្នុងរឿងកាត់ក្តី ឬពីអ្នកឯទៀតណាក៏ដោយ ។

២. ចៅក្រមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ឬក្រោមភាគីនយោបាយណាឡើយ ។ ជនដែលត្រូវគេជ្រើសរើសឱ្យបំពេញមុខងារក្នុងតុលាការ ត្រូវតែជាអ្នកសុចរិត និងមានសមត្ថភាពផង ។

៣. គោលការណ៍ឯករាជ្យភាពនៃចៅក្រមប្រគល់សិទ្ធិ និងករណីយកិច្ចជូនចៅក្រម ដើម្បីធានាឱ្យការកាត់ក្តីប្រព្រឹត្តទៅក្នុងភាពសុចរិត និងក្នុងការគោរពដល់សិទ្ធិនៃភាគីដែលត្រូវកាត់ក្តីទាំងអស់ ។ ចៅក្រមត្រូវមានលទ្ធភាពបំពេញមុខងារខ្លួនតាមស្ថានភាពសម្ភារៈសមរម្យ និងគ្រប់គ្រាន់ ។ ចៅក្រមត្រូវទទួលការហ្វឹកហ្វឺនត្រឹមត្រូវ មានប្រាក់បៀវត្សគ្រប់គ្រាន់ ដើម្បីធានានូវភាពឥតលម្អៀង និងឯករាជ្យភាពរបស់ពួកគេ ។

១៨. អនុលោមទៅតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌអ៊ុនតាក់ (អាចអនុវត្តជាធរមាននៅឆ្នាំ ២០០២ និងរហូតដល់សព្វថ្ងៃ)៖

**មាត្រា ៣៨ : ការជំរិតទារប្រាក់**[24]

១. ដោយមិនគិតដល់ទណ្ឌកម្មខាងវិន័យជាយថាហេតុ គ្រប់អ្នករដ្ឋបាលស៊ីវិល ឬយោធា គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងចំណោមភាគីទាំងបួននៃកិច្ចព្រមព្រៀងប៉ារីស គ្រប់អ្នកទទួលខុសត្រូវនយោបាយដែលស្នើសុំ ឬប៉ុនប៉ងនឹងស្នើសុំ ឬ ទទួល ឬប៉ុនប៉ងនឹង ទទួលក្នុងក្របខណ្ឌនៃ

[24] ការបកប្រែមួយផ្សេងទៀតនៃក្រមអ៊ុនតាក់នេះ បកប្រែថា មាត្រាដដែលនេះថាជា "អំពើពុករលួយ"។ សម្រាប់ការបកប្រែដែលស្រដៀងនឹងពាក្យខ្មែរគឺត្រឹមតែហៅថា "ការស៊ីសំណូក" (bribe-taking)។

ការងារខ្លួន ឬក្នុងឱកាសបំពេញការងារ នូវទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់កាស បុគ្គល មុខងារ ឯកសារ សេចក្តីអនុញ្ញាត ឬផលប្រយោជន៍អ្វីមួយ ជាថ្នូរនៃរបស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គឺបានប្រព្រឹត្តនូវបទឧក្រិដ្ឋស៊ីសំណូកអកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋបីឆ្នាំទៅប្រាំពីរឆ្នាំ ។

២. ជនដែលបានប្រព្រឹត្តបទល្មើសខាងលើនេះ នឹងអាចត្រូវតុលាការដកហូតមុខងារចេញពីអាណត្តិនៃការជ្រើសតាំងរបស់ខ្លួន ហើយម្យ៉ាងទៀតនឹងអាចហាមឃាត់មិនអោយឈរឈ្មោះក្នុងអាណត្តិនៃការបោះឆ្នោត ឬមិនអោយកាន់មុខតំណែងដែលមានការទទួលខុសត្រូវណាមួយក្នុងរដ្ឋបាលសាធារណៈក្នុងរយៈពេលពីរឆ្នាំ ក្រោយបានពីរងទោសរបស់ខ្លួនរួចហើយ ។

៣. ម្យ៉ាងទៀត ជនប្រព្រឹត្តបទឧក្រិដ្ឋនោះ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងពីរដងនៃតម្លៃទ្រព្យសម្បត្តិ ឬទឹកប្រាក់ដែលបានគៃបំបាត់ដោយបន្លំនោះ[25] ។

១៩. អនុលោមទៅតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបានបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ នៅក្នុងបរិបទនេះ៖ ក) ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌..." ។

២០. អនុលោមទៅតាមវិធាន ៣៤(២) នៃវិធានផ្ទៃក្នុង "ភាគីអាចធ្វើបណ្តឹងជំទាស់ចិត្តចំពោះចៅក្រមក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពឥតលម្អៀង" ។

២១. អនុលោមទៅតាមមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) "ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេច

---

[25] ទង្វើនេះក៏ត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌនៅប្រទេសផ្សេងទៀតដែរ ។ ឧទាហរណ៍ ក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំង ដាក់ទណ្ឌកម្មចំពោះការទទួលយកសំណូក ដោយអ្នកដែលមានតួនាទីនៅក្នុងតុលាការ ។ សូមមើលក្រមព្រហ្មទណ្ឌបារាំង N.C PEN., Art 434-9 ។

00636106



លើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី"។

២២. អនុលោមទៅតាមមាត្រា ២ ដល់មាត្រា ៤ នៃក្រមសីលធម៌ចៅក្រមកម្ពុជាចែងថា ចៅក្រមត្រូវតែឯករាជ្យ អនាគតិ និងស្មោះត្រង់ ។ ស្រដៀងគ្នានេះដែរ អនុលោមតាមមាត្រា ១ ដល់មាត្រា ៣ នៃក្រមសីលធម៌ចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញ៖

**មាត្រា ១ ៖ ឯករាជ្យភាពរបស់តុលាការ**

១. ចៅក្រមត្រូវរក្សានូវឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អវតក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិ អំណាច និងឯករាជ្យភាពក្នុងការបំពេញតួនាទីរបស់ខ្លួន ។

២. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួន ។

**មាត្រា ២ ៖ អនាគតិ**

១. ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះក្នុងការបំពេញតួនាទីរបស់ខ្លួន ។

២. ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានជម្លោះផលប្រយោជន៍កើតឡើង ។

**មាត្រា ៣ ៖ សុចរិតភាព**

**(ធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨)**

១. ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និងដោយសេចក្ដីសុចរិតទៀងត្រង់តាមការិយាល័យរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ ។

២. ចៅក្រមមិនត្រូវទទួលយក ឬសំណើផ្ដល់ ឬផ្ដល់នូវអំណោយ (កាដូ) ផលប្រយោជន៍ បុព្វសិទ្ធិ ឬរង្វាន់ ទោះដោយផ្ទាល់ក្ដី ឬដោយប្រយោជន៍ក្ដី ដែលគេអាចយល់បានថាកំពុងតែមានចេតនាជះឥទ្ធិពលលើការបំពេញមុខនាទី ឬឯករាជ្យភាពនៃការងាររបស់ខ្លួន[26] ។

២៣. ច្បាប់កម្ពុជា និងក្រមសីលធម៌ចៅក្រមកម្ពុជា និងក្រមសីលធម៌ចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញ

---

[26] អនុម័តដោយកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ។ សូមមើលផងដែរមាត្រា៤ នៃក្រមសីលធម៌ចៅក្រមនៅ ICC ដែលបានអនុម័ត និងចូលជាធរមាននៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៥ ដែលពិពណ៌នាពីមុខនាទីដោយឥតលម្អៀងរបស់ចៅក្រម ដែលប្រើពាក្យដូចគ្នានឹងក្រមសីលធម៌ចៅក្រមនៅ អវតក ដែរ ។

មិនមែនមានតែឯងនៅកម្ពុជានោះទេ នៅក្នុងការតម្រូវឲ្យចៅក្រមបំពេញមុខនាទីដោយឯករាជ្យ ឥតលម្អៀង និងដោយសុចរិតភាពនោះទេ។ រដ្ឋជាច្រើនមានលក្ខខណ្ឌតម្រូវស្រដៀងៗគ្នានៅក្នុងក្រមសីលធម៌ចៅក្រមរបស់គេ។ ឧទាហរណ៍ យោងទៅតាម សេចក្ដីណែនាំសម្រាប់ក្រមសីលធម៌ចៅក្រមនៃប្រទេសញូហ្សេឡាន (New Zealand Guidelines for Judicial Conduct) "អនាគតិ គឺជាគុណសម្បត្តិតម្រូវដ៏សំខាន់សម្រាប់ចៅក្រម"[27] ហើយ "ការកង្វះខាតសុចរិតភាព ឬភាពស្មោះត្រង់ នៅក្នុងការដោះស្រាយវិវាទឯកជន និងកិច្ចការហិរញ្ញវត្ថុជាដើម នោះចៅក្រមនឹងទទួលរងនូវការរិះគន់ពីបុគ្គលដែលសមហេតុផល មិនលម្អៀង និងទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយក៏អាចគេយល់ឃើញថា ជាចៅក្រម ដែលមិនសក្ដិសមនឹងបំរើការងារក្នុងវិស័យតុលាការទៀតផង"[28]។

២៤. អនុលោមទៅតាមតម្លៃ ១ ដល់ ៤ នៃគោលការណ៍ Bangalore ស្ដីពីក្រមសីលធម៌ចៅក្រម ("គោលការណ៍ Bangalore")[29]

---

[27] នៅកថាខណ្ឌទី៨ នៃសេចក្ដីណែនាំសម្រាប់ការបំពេញមុខនាទីជាចៅក្រមនៃប្រទេស ញូហ្សេឡែន ។ អាចរកបាននូវឯកសារនេះនៅ http://www.courtsofnz.govt.nz/business/guidelines/guidelines-for-judicial-conduct/Guidelines-for-Judicial-Conduct.pdf.

[28] ដូចខាងលើ កថាខណ្ឌទី៣៥ ។

[29] គោលការណ៍ Bangalore មានបញ្ចូលនូវការសិក្សាលើកដំបូងទីមួយក្នុងចំណោមការសិក្សាជាច្រើន ទាក់ទងទៅនឹងក្រមសីលធម៌ក្រម ហើយគោលការណ៍នេះមានបំណងយកទៅអនុវត្តចំពោះចៅក្រមទាំងអស់នៅទូទាំងពិភពលោក ។ ក្រុមការងារទទួលបន្ទុកក្រមសីលធម៌ចៅក្រម បណ្ដាញសហគមអឺរ៉ុបនៃក្រុមប្រឹក្សាយុត្តិធម៌ និង Consiglio Superiore Della Magistratura, នៅទំព័រ២៥ ។ គោលការណ៍ Bangalore ត្រូវបានគេយោងថាជា "លិខិតុបករណ៍អន្តរជាតិប្រសើរជាងគេទាក់ទងទៅនឹងក្រមសីលធម៌ចៅក្រម" ។ សូមមើលគណៈមេធាវីសហរដ្ឋអាមេរិក "ការវិភាគនៃសេចក្ដីព្រាងក្រមសីលធម៌ចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៥ នៅទំព័រ២។ គោលការណ៍ Bangalore ត្រូវបានលើកយកមកសំអាងដោយអង្គបុរេជំនុំជម្រះ ។ សូមមើលករណី អៀង សារី ០០២/០៩-១០-២០០៩-អវតក/អបជ(០១), សាលដីកាលើពាក្យបណ្ដឹង របស់ អៀង សារី សុំដិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩, ERN: 00407716-00407724 នៅកថាខណ្ឌទី១៩ ។ គោលការណ៍ Bangalore ត្រូវបានបង្កើតឡើងដើម្បីពង្រឹងគោលការណ៍មូលដ្ឋានឆ្នាំ ១៩៨៥របស់អង្គការសហប្រជាជាតិស្ដីពីឯករាជ្យភាពតុលាការ ហើយក្នុងចំណោមបញ្ហាដទៃទៀត ត្រូវបានគាំទ្រដោយឧត្ដមស្នងការរបស់អង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស និងត្រូវបានពង្រាងដោយក្រុមការងារសុចរិតភាពតុលាការនៅឆ្នាំ២០០១ ហើយត្រូវបានពិនិត្យសារជាថ្មីឡើងវិញនៅឆ្នាំ២០០២ ។ សេចក្ដីពង្រាងទាំងនេះត្រូវបានពិនិត្យសារជាថ្មីឡើងវិញ ដោយអនុលោមតាម ការអត្ថាធិប្បាយពីយុត្តាធិការច្បាប់ស៊ីវិល និងច្បាប់កុម៉ង់ឡូ ។ សម្រាប់ការពិពណ៌នាអំពីដំណើរការនេះ *សូមមើល* ក្រុមការងារសុចរិតភាពតុលាការ "*ការអធិប្បាយទៅលើគោលការណ៍ Bangalore ស្ដីពីក្រមចរិយាធម៌របស់ចៅក្រម*' បោះពុម្ពផ្សាយ ខែមីនា ឆ្នាំ២០០៧ នៅទំព័រ៩-១៨ . អាចរកបាននៅ: http://www.coe.int/t/dghl/cooperation/ccje/textes/Bangalore

00636108



*តម្លៃ១:*

**ឯករាជ្យភាព**

*គោលការណ៍:*

ឯករាជ្យភាពនៃតុលាការ គឺជាបុរេលក្ខខណ្ឌចំពោះនីតិរដ្ឋ និងជាមូលដ្ឋានគ្រឹះសម្រាប់ការធានាការកាត់ក្តីដោយយុត្តិធម៌ ។ ហេតុដូច្នេះចៅក្រមត្រូវប្រកាន់ភ្ជាប់នូវឯករាជ្យភាព ទាំងនៅក្នុងទិដ្ឋភាពជាបុគ្គល និងទិដ្ឋភាពជាស្ថាប័ន ។

*ការអនុវត្ត:*

១.១ ចៅក្រមត្រូវបំពេញមុខនាទីដោយឯករាជ្យ ដោយផ្អែកលើការវាយតម្លៃរបស់ចៅក្រមលើអង្គហេតុ និងដោយអនុលោមតាមការយល់ដឹងពីច្បាប់ដែលប្រកបដោយមនសិការ និងរួចផុតពីឥទ្ធិពលពីខាងក្រៅ ការបញ្ចុះបញ្ចូល ការគាបសង្កត់ គំរាមកំហែង ឬ ការជ្រៀតជ្រែកណាមួយដោយផ្ទាល់ ឬ ប្រយោលពីបណ្តាជនណាមួយ ឬដោយមូលហេតុណាមួយ ។

...

១.៣ ចៅក្រមមិនត្រឹមតែមិនជាប់ពាក់ព័ន្ធដោយមិនសមរម្យជាមួយ និងមិនទទួលរងឥទ្ធិពលពីអង្គនីតិប្រតិបត្តិ និងអង្គនីតិបញ្ញត្តិរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ តែថែមត្រូវឱ្យអ្នកសង្កេតការឥតលម្អៀងមើលឃើញថាចៅក្រមរូបនេះត្រូវតែមិនជាប់ពាក់ព័ន្ធដោយមិនសមរម្យជាមួយ និងទទួលរងឥទ្ធិពលពីអង្គនីតិប្រតិបត្តិ និងអង្គនីតិបញ្ញត្តិរបស់រដ្ឋាភិបាលទៀតផង ។

...

១.៥ ចៅក្រមត្រូវជំរុញ និងប្រកាន់ខ្ជាប់ការការពារសម្រាប់ការបំពេញមុខនាទីតុលាការ ដើម្បីរក្សា និងពង្រឹងស្ថាប័ន និងការប្រព្រឹត្តទៅនៃឯករាជ្យភាពតុលាការ ។

...

*តម្លៃ២:*

**អនាគតិ**

*គោលការណ៍:*

អនាគតិ គឺមានសារៈសំខាន់ណាស់ក្នុងបំពេញមុខនាទីយ៉ាងត្រឹមត្រូវនូវកិច្ចការតុលាការ ។ គោលការណ៍អនាគតិនេះ មិនត្រឹមតែអនុវត្តលើសេចក្តីសម្រេចប៉ុណ្ណោះទេ ប៉ុន្តែក៏អនុវត្តចំពោះដំណើរការក្នុងការធ្វើសេចក្តីសម្រេចផងដែរ។

*ការអនុវត្តន៍:*

---

PrinciplesComment.PDF. *សូមមើលផងដែរ* ECOSOC Resolution 2007/22, *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://www.un.org/ecosoc/docs/2007/Resolution%202007-22.pdf.

២.១ ចៅក្រមត្រូវតែបំពេញមុខនាទីរបស់ខ្លួនដោយមិនគាំទ្រ (favour) មិនលម្អៀង ឬ មិនមានបុរេវិនិច្ឆ័យ។

២.២ ចៅក្រមត្រូវធានាថាការបំពេញមុខនាទីរបស់ខ្លួន ទាំងក្នុងនិងក្រៅតុលាការ ត្រូវរក្សា និងពង្រឹងទំនុកចិត្តពីសាធារណៈជន អ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងគូវិវាទក្នុងរឿងក្តី ទៅលើភាពអនាគតិរបស់ចៅក្រម និងអនាគតិរបស់តុលាការ ។

...

*តម្លៃ៣:*

**សុចរិតភាព**

*គោលការណ៍:*

សុចរិតភាព មានសារៈសំខាន់ណាស់ក្នុងការបំពេញមុខងារយ៉ាងត្រឹមត្រូវនូវកិច្ចការតុលាការ។

*ការអនុវត្តន៍:*

៣.១ <u>ចៅក្រមត្រូវតែធានាថាការបំពេញមុខងាររបស់ខ្លួន មិនត្រូវទទួលការចាប់កំហុសពីអ្នកសង្កេតការឥតលម្អៀង</u>។

៣.២ ឥរិយាបទ និងការប្រព្រឹត្តរបស់ចៅក្រម ត្រូវតែទទួលបានការជឿជាក់របស់ប្រជាជនទៅលើសុចរិតភាពរបស់តុលាការ។ <u>យើងមិនត្រឹមតែធ្វើឱ្យមានយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវតែធ្វើឱ្យគេមើលឃើញថាយុត្តិធម៌ពិតជាមានមែន ។</u>

...

*តម្លៃ៤:*

**ភាពស្មោះត្រង់ (PROPRIETY)**

*គោលការណ៍:*

ភាពស្មោះត្រង់ និងការបង្ហាញពីភាពស្មោះត្រង់ គឺពិតជាមានសារៈសំខាន់ដល់គ្រប់សកម្មភាពទាំងអស់របស់ចៅក្រម។

*ការអនុវត្តន៍:*

៤.១ ចៅក្រមត្រូវតែចៀសវាងការប្រព្រឹត្តមិនសមរម្យ និងការបង្ហាញពីការប្រព្រឹត្តមិនសមរម្យក្នុងគ្រប់សកម្មភាពទាំងអស់របស់ខ្លួន។

...

00636110



៤.១៤ ចៅក្រម និងសមាជិកគ្រួសាររបស់ចៅក្រមមិនត្រូវស្នើសុំ ហើយក៏មិនត្រូវទទួលយកការដូរ លុយកាក់ ប្រាក់កម្ចី ឬការគាំទ្រទាក់ទងនឹងអ្វីដែលបានធ្វើ ឬនឹងធ្វើ ឬចង់ធ្វើដោយដោយចៅក្រមទាក់ទងនឹងការអនុវត្តន៍កាតព្វកិច្ចរបស់តុលាការ[30]។

## ខ.ការវាយតម្លៃអំពី*ភាពលម្អៀង ឬការលេចឡើងនៃភាពលម្អៀង*

២៥. អវតក អនុវត្តតាមការវាយតម្លៃពីភាពលម្អៀងដែលបង្កើតដោយអង្គជំនុំជម្រះតុលាការកំពូល ICTY នៅក្នុងរឿងក្តី *Furundžija*[31] ។ នៅក្នុងរឿងក្តី *Furundžija* អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "មានវិធានទូទៅថាចៅក្រមមិនត្រឹមតែគ្មានភាពលម្អៀងជាអត្តនោម័តប៉ុណ្ណោះទេ ប៉ុន្តែចៅក្រមថែមទាំងមិនបង្ហាញនូវភាពលម្អៀងជាក់ស្តែងទៀតផង ទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ[32]"។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងនូវគោលការណ៍ដូចខាងក្រោម៖

ក. ចៅក្រមមិនមានអនាគតិទេ ប្រសិនបើភាពលម្អៀងជាក់ស្តែងកើតឡើង ។

ខ. មានការលេចឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបានប្រសិនបើ៖

i) ចៅក្រមគឺជាភាគីនៃរឿងក្តី ឬក៏មានផលប្រយោជន៍ខាងសម្ភារៈ ឬហិរញ្ញវត្ថុដែលបានមកពីលទ្ធផលនៃរឿងក្តីនោះ ឬការសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឱ្យមានការបន្ថែមបុព្វហេតុដែលខ្លួនជាប់ពាក់ព័ន្ធជាមួយនឹងភាគីមួយក្នុងចំណោមភាគីដទៃទៀត ។ នៅក្នុងកាលៈទេសៈបែបនេះ ការដកចៅក្រមចេញពីរឿងក្តីនេះ ត្រូវធ្វើឡើងជាស្វ័យប្រវត្តិ ឬ

ii) កាលៈទេសៈទាំងឡាយ ដែលធ្វើឱ្យអ្នកសង្កេតការមិនលម្អៀងដែលបានទទួលព័ត៌មានពេញលេញ យល់ឃើញថាពិតជាមានភាពលម្អៀង[33]។

២៦. ទាក់ទងនឹងការយល់ឃើញដោយអ្នកសង្កេតការមិនលម្អៀងទៅលើគោលការណ៍ទី២នេះ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Furundžija* បានទទួលយកនូវ "វិធីសាស្ត្រដែលថា "អ្នកសង្កេតការមិនលម្អៀង ត្រូវតែជាបុគ្គលដែលទទួលបានព័ត៌មានពេញលេញ ហើយបានដឹងឮគ្រប់កាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិ ដែលបង្កើតបានផ្នែកមួយនៃប្រវត្តិសាវតារ និងផ្តល់ជាដំណឹងថាភាពឥតលម្អៀង គឺជាមុខនាទីមួយដែល

---

[30] គោលការណ៍ Bangalore ស្តីពីក្រមចរិយាធម៌របស់តុលាការ, ឆ្នាំ២០០២, អាចស្វែងរកមើលបាននៅគេហទំព័រ http://www.unodc.org/pdf/crime/corruption/judicial_group/Bangalore_principles.pdf. (គូសបញ្ជាក់បន្ថែម)។

[31] សាលដីកាលើបណ្តឹងជិតចិត្ត ន័យ ផុល កថាខណ្ឌទី២០។

[32] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Furundžija* IT-95-17/1-A, សាលក្រម,ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២000, ត្រង់កថាខណ្ឌទី១៨៩។

[33] ដូចគ្នា។

ចៅក្រមត្រូវតែប្រកាន់ខ្ជាប់""[34]។

## IV. ពាក្យបណ្តឹងជំទាស់

### ក. ការសង្កេតជាបឋម

២៧. ចៅក្រម ដែលពុករលួយមិនបានបំពេញការងារដោយឯករាជ្យ ដោយអនាគតិ ឬ ដោយមានសុចរិតភាពទេ។ "អំពើពុករលួយគំរាមកំហែងដល់នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ធ្វើអោយខូចខាតដល់អភិបាលកិច្ចល្អ ភាពត្រឹមត្រូវ និងយុត្តិធម៌សង្គម ធ្វើអោយបាត់បង់ការប្រកួតប្រជែង រាំងស្ទះការរីកចំរើនវិស័យសេដ្ឋកិច្ច និងធ្វើអោយគ្រោះថ្នាក់ដល់ស្ថេរភាពនៃស្ថាប័នប្រជាធិបតេយ្យ និងសីលធម៌ដែលជាគ្រឹះនៃសង្គម"[35]។ រដ្ឋាភិបាលនានាពុះពារក្នុងការលុបបំបាត់អំពើពុករលួយក្នុងប្រព័ន្ធតុលាការ ដើម្បីធានាថា ចៅក្រមធ្វើការដោយឯករាជ្យ ឥតលំអៀង និងស្អាតស្អំ (សុចរិត) ដែលមុខតំណែងរបស់អ្នកទាំងនោះតម្រូវ។ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ទទូចចង់បានដូច្នេះនៅពេលដែលគាត់បង្កើតយុទ្ធនាការ "កណ្តាប់ដៃដែក" ក្នុងឆ្នាំ២00៥ ដើម្បីបង្ក្រាបអំពើពុករលួយរបស់ចៅក្រម[36]។

២៨. និយាយអំពីភាពចាំបាច់អោយមានចៅក្រមដែលមិនពុករលួយ ចៅក្រមជាន់ខ្ពស់ Justice Michael Kirby ដែលជាអតីតប្រធានតុលាការកំពូលអូស្ត្រាលី បានកត់សម្គាល់យ៉ាងប្រណិតថា "ច្បាប់អាច

[34] ដូចគ្នា, កថាខណ្ឌទី១៩0, ដកស្រង់ ករណី R.D.S តទល់នឹង ម្ចាស់ក្សត្រី (ឆ្នាំ១៩៩៧) Can. Sup. Ct, ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៧។ តុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអូន បានអនុវត្តការវាយតម្លៃដូចគ្នានេះ។ ទាក់ទងទៅនឹង ការយល់ឃើញរបស់អ្នកសង្កេតការឯករាជ្យ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា "ទាក់ទងនឹងការវាយតម្លៃ ជាសត្យានុម័ត ការវាយតម្លៃនេះ តម្រូវឲ្យចៅក្រមមិនត្រឹមតែមានភាពមិនលម្អៀងប៉ុណ្ណោះទេ <u>ប៉ុន្តែត្រូវធ្វើឲ្យគេមើលឃើញ ថាមិនលម្អៀងផងដែរ</u>។ ជាងនេះទៅទៀត ចំណុចសំខាន់នៃភាពទំនងជាមានភាពលម្អៀង មិនចាំបាច់ទាល់តែមាន ភស្តុតាងទាក់ទងនឹងភាពលម្អៀងជាក់ស្តែងនោះទេ"។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Sesay et al.*, SCSL-04-15-T, សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍របស់ Sesay, Kallon និង Gbao ប្រឆាំងទៅនឹងសេចក្តីសម្រេចលើបណ្តឹងរបស់ Sesay និង Gbao សុំដក ឬសុំជំទាស់ Hon. Justice Bankole Thompson ពីរឿងក្តី RUF ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២00៨, កថាខណ្ឌទី៩ (គូសបញ្ជាក់បន្ថែម)។

[35] ក្រុមប្រឹក្សាអឺរ៉ុប អនុសញ្ញាច្បាប់ព្រហ្មទណ្ឌអន្តរជាតិស្តីពីអំពើពុករលួយ ២៧ មករា ១៩៩៩ បុព្វកថា *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://conventions.coe.int/Treaty/EN/Treaties/Html/173.htm.។

[36] *សូមមើល* អង្គការលីកាដូ *សិទ្ធិមនុស្សនៅកម្ពុជា៖ យុត្តិធម៌ក្លែងក្លាយ (Human Rights in Cambodia: the Charade of Justice)* ចេញផ្សាយខែ ធ្នូ ២00៧ ទំព័រ ២២ *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://www.licadho-cambodia.org/reports/files/113LICADHOReportCharadeJustice07.pdf.។

ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ ប៉ុន្តែក្តីសង្ឃឹមអោយមានចៅក្រមមិនពុករលួយគឺ ឬគួរតែមានជាសាកល"[37]។ ដូច្នេះហើយ គ្មានអ្វីភ្ញាក់ផ្អើលទេ ដែលចៅក្រម Sylvia Cartwright នៅពេលមានមតិយោបល់អំពីការចូលរួមរបស់គាត់ជាចៅក្រមនៅ អវតក និងលទ្ធភាពនៃដំណើរការរបស់ អវតក ដែលកំពុងរងការខូចខាតដោយអំពើពុករលួយ បានថ្លែងថា "ចៅក្រមមួយចំនួននឹងវេចបង្វេច ហើយចាកចេញទៅ"[38]។ ការអត់អោនដល់ចៅក្រមម្នាក់អោយបន្តចូលរួមជំរះក្តីដែលចៅក្រមនោះជិតដាមដោយប្រវត្តិនៃការស៊ីសំណូកជាក់ស្តែង គឺច្បាស់ជាទម្រង់មួយនៃអំពើពុករលួយ។ "**បើសិនជានៅពេលដែលប្រឈមមុខនឹងភស្តុតាងនៃការជ្រៀតជ្រែក មន្ត្រីបុគ្គលិកអន្តរជាតិរបស់តុលាការពន្យារ ឬមិនមានចេតនាយកមកប្រើប្រាស់បទបញ្ញត្តិច្បាប់មករារាំង អ្នកទាំងនោះប្រែក្លាយជាចូលដៃចូលជើងដែរ**"[39]។

២៩. លោក អៀង សារី មានសិទ្ធិដែលគ្មានដែនកម្រិតក្នុងការទទួលបានការកាត់សេចក្តីដោយតុលាការដែលឯករាជ្យ និងឥតលំអៀង[40]។ ដូច្នេះ លោក អៀង សារី មានសិទ្ធិក្នុងការរំពឹងទុកថា ចៅក្រមទាំងឡាយដែលកាត់សេចក្តីរឿងក្តីរបស់គាត់ នឹងធ្វើការដោយឯករាជ្យ អនាគតិ និងស្អាតស្អំ។ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែដោះស្រាយអោយបានហ្មត់ចត់ទៅលើពាក្យបណ្តឹងជិតចិត្តនេះ

---

[37] អត្ថបទរបស់ Michael Kirby ក្រោមចំណងជើងថា *ប្រយុទ្ធប្រឆាំងអំពើពុករលួយលើសកលលោក* (*Tackling Judicial Corruption Globally*) *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://www.hcourt.gov.au/speeches/kirbyj/kirbyj_stjames.htm.។

[38] *ការងារតឹងតែងនាអនាគតសម្រាប់ចៅក្រមញូវហ្សេលែន (Tough Job Ahead for NZ Judge)* TVNZ ២៩ មីនា ២០០៩ *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://tvnz.co.nz/world-news/tough-job-ahead-nz-judge-2594965.។

[39] របាយការណ៍របស់ OSJI ទំព័រ ២៣។ អង្គការគំនិតផ្តួចផ្តើមសង្គមសេរី (Open Society Justice Initiative) ថ្លែងបន្ថែមថា "ខណៈដែលបុគ្គលិកអន្តរជាតិមិនចាំបាច់ធ្វើជាអ្នកត្រួតពិនិត្យលើសហសេវិកជាតិរបស់ពួកគេ អ្នកទាំងនេះត្រូវតែក្លាយជាអ្នកការពារដ៏សកម្មនូវសុចរិតភាពរបស់តុលាការ និងមិនអាចមិនអើពើ ឬទទួលយកនូវស្ថានភាពទាំងនេះនៅពេលដែលការជ្រៀតជ្រែកខាងនយោបាយលេចចេញយ៉ាងច្បាស់នោះ។ ការទទួលខុសត្រូវនេះគឺមានខ្ពស់ឡើងៗ នៅក្នុងករណីនៃដំណើរការនីតិវិធីតុលាការដែលប្រព្រឹត្តជាសម្ងាត់នោះ" របាយការណ៍របស់ OSJI ទំព័រ ៣០។

[40] ភាពចាំបាច់នៃគុណភាពនៃឯករាជ្យភាព និងអនាគតិគឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ អតីតប្រធាន និងបច្ចុប្បន្នជាចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ICTY ចៅក្រម Theodor Meron បានពន្យល់ថា "គេត្រូវរំលឹកឡើងវិញថាចៅក្រមដែលមិនឯករាជ្យអាចពិបាកមានអនាគតិណាស់" ។ អត្ថបទរបស់ Theodor Meron ក្រោមចំណងជើងថា *ឯករាជ្យភាព និងអនាគតិរបស់ចៅក្រមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (Judicial Independence and Impartiality in International Criminal Tribunals)*, 99 AM. J. INT'L L. 359, 361 (2005) ("Meron") ។

00636113



ហើយ ដូចដែលបានស្នើនៅក្នុងសំណើសុំអោយស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូងត្រូវចាត់វាល់វិធានការចាំបាច់ទាំងអស់ ដើម្បីធ្វើអោយប្រាកដថា ចៅក្រម និល ណុន ពិតជាបានឆ្លើយទទួលស្គាល់ដោយមានកំហុសទាក់ទងនឹងខ្លួនគាត់ផ្ទាល់នៅក្នុង Frontline/World និងកាសែតឌីខេមបូឌៀដេលី ដូចដែលបានបង្ហាញដោយអ្នកនាង Pike។

**ខ. ការយល់ឃើញថា ចៅក្រម និល ណុន បានទទួលស្គាល់ថាបានយកប្រាក់កាសពីភាគីវិវាទ បង្កើតអោយមានមន្ទិលសង្ស័យទៅលើ ឯករាជ្យភាព អនាគតិ និងសុចរិតភាពរបស់គាត់ ដែលទំនងជាបង្កើតអោយមានភាពលំអៀង**

៣០. ចៅក្រម និល ណុន ទំនងជាបានឆ្លើយទទួលស្គាល់ជាសាធារណៈថាបានទទួលយកសំណូក ថ្វីបើគាត់អះអាងថា រឿងទាំងនេះគឺគ្រាន់តែជាការដឹងគុណរបស់គូវិវាទដែលឈ្នះក្តីក៏ដោយ[41]។ នេះគឺជាអំពើមួយបែបដែលរារាំងចៅក្រមម្នាក់ មិនអោយបំពេញកិច្ចការតុលាការរបស់ខ្លួនដោយឯករាជ្យ និង អនាគតិ។ ម្យ៉ាងវិញទៀត ការយល់ឃើញថាជាការឆ្លើយទទួលស្គាល់អំពើបែបនេះរបស់ចៅក្រម និល ណុន គឺរំលោភបំពានច្បាប់កម្ពុជា[42] ក្រមសីលធម៌របស់គាត់ (ដែលនៅជាធរមាននៅពេលនោះ និងក្រមសីលធម៌ អវតក)[43] និងបទដ្ឋានយុត្តិធម៌អន្តរជាតិ។ ហេតុដូច្នេះសន្មតថា ខ្សែភាពយន្តធ្វើអោយមានសុពលភាពដល់ការអះអាងរបស់អ្នកនាង Pike ដែលបានលើកឡើងទាំងនៅក្នុងអត្ថបទសរសេរទាំងឡាយរបស់គាត់ និងទាំងទៅកាសែតឌីខេមបូឌៀដេលីមែននោះ ចៅក្រម និល ណុន *ដាច់ខាត*ត្រូវតែដកគុណវុឌ្ឍិចេញអនុលោមទៅតាមវិធាន ៣៤។

៣១. វិធាន ៣៤ អនុញ្ញាតអោយភាគីណាមួយស្នើសុំដិតចិត្តចៅក្រមម្នាក់ "ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៏ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែល<u>អាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលំអៀង</u>។[44]" ជាមួយគ្នានេះដែរ ចៅក្រមមិនមែនគ្រាន់តែ<u>មានភាព</u>ឯករាជ្យ និងឥតលំអៀង

---

[41] ដូចដែលពិភាក្សានៅទំព័រខាងក្រោយ ពេលវេលាគឺមិនមានសារៈសំខាន់ ហើយការបានទទួលយកប្រាក់កាសនៅពេលណាមួយក៏ដោយដែលទាក់ទងនឹងរឿងក្តីមួយ គឺត្រូវបានហាមឃាត់ដូចគ្នាដោយច្បាប់ និងដោយក្រមសីលធម៏ចៅក្រមដែលត្រូវយកមកអនុវត្ត។

[42] *សូមមើល* ក្រមអ៊ិនតាក់ មាត្រា ៣៨ ។

[43] *សូមមើល* ក្រមសីលធម៏ចៅក្រម មាត្រា ២ ដល់ ៤ ។

[44] គូសបញ្ជាក់បន្ថែម។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "លក្ខណៈវិនិច្ឆ័យដែលត្រូវយកមកប្រើ ... គឺមានចែងនៅក្នុងវិធានផ្ទៃ ក្នុង ៣៤.២ ... ដែលយោងទៅលើការលំអៀងជាក់ស្តែង ឬអាការៈលំអៀង" សាលដីកាបណ្តឹងដិតចិត្ត ន័យ ធុល កថាខណ្ឌ

00636114



ប៉ុណ្ណោះទេ ចៅក្រមត្រូវតែធ្វើអោយអ្នកសង្កេតការឥតលំអៀងឃើញថាមានឯករាជ្យភាព និងអនាគតិផងដែរ។ នេះក៏ព្រោះ "ឯករាជ្យភាពរបស់តុលាការ ... ពឹងផ្អែកទៅលើការគាំទ្ររបស់សាធារណជនទៅលើស្ថាប័នតុលាការ និងទទួលបានការគាំទ្រដែលតុលាការត្រូវតែសម្តែងមកខាងក្រៅថាមានអនាគតិយ៉ាងហ្មត់ចត់ក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន" ។ ជាមួយគ្នានឹងភក្តីភាពចំពោះច្បាប់ អនាគតិគឺជាមធ្យោបាយមួយធានាអោយមានទំនួលខុសត្រូវរបស់តុលាការដែលឯករាជ្យមួយ នៅក្នុងប្រទេសប្រជាធិបតេយ្យ និងនៅក្នុងសហគមន៍អន្តរជាតិ[45]។ ដោយសារយុត្តិធម៌ត្រូវតែធ្វើអោយគេឃើញថាមានយុត្តិធម៌ តុលាការជាតិ[46] និងអន្តរជាតិ[47] ជាធម្មតាបានយល់ឃើញថា ចៅក្រមទាំងឡាយត្រូវតែដកខ្លួនចេញ ឬ ត្រូវគេដកគុណវុឌ្ឍិ បើសិនជាចៅក្រមទាំងនោះមានភាពលំអៀងជាក់ស្តែង ឬមានការលេចចេញមកខាងក្រៅដែលទំនងជាមាន

---

១២។ "យុត្តិសាស្ត្រនៃតុលាការអន្តរជាតិនានា គឺមានលក្ខណៈស៊ីសង្វាក់គ្នាចំពោះលក្ខណៈវិនិច្ឆ័យនៃការលំអៀងនៅទីនេះ" *ដូចយោងខាងលើ* កថាខណ្ឌ ២០ ។

[45] Meron នៅទំព័រ ៣៦៩ ។ អាការៈលំអៀងគឺមានសារៈសំខាន់ដោយសារ "ឧទាហរណ៍ ចៅក្រមម្នាក់អាចមានលទ្ធភាពចេញសេចក្តីសម្រេចដែលមិនលំអៀង សូម្បីតែចៅក្រមនោះជាសមាជិកនៃអង្គការដែលមានការរើសអើងក៏ដោយ ប៉ុន្តែជាជាងធ្វើអោយសាធារណជនមានទំនុកចិត្ត ចៅក្រមត្រូវបានហាមឃាត់មិនអោយធ្វើជាសមាជិកនៃអង្គការដែលអនុវត្តការរើសអើងដែលមិនជាទីពេញចិត្ត។ ស្រដៀងគ្នា ចៅក្រមម្នាក់អាចមានលទ្ធភាពចេញសេចក្តីសម្រេចដែលមានយុត្តិធម៌មួយ សូម្បីតែក្មួយរបស់ខ្លួនគឺជាមេធាវីនៅក្នុងរឿងក្តីនោះ ប៉ុន្តែជាជាងផ្តល់អោយភាគីនូវមូលដ្ឋានសម្រាប់ដាក់ចំណោទលើសេចក្តីសម្រេច ចៅក្រមត្រូវតម្រូវអោយដកគុណវុឌ្ឍិ"។ អត្ថបទរបស់ Cynthia Gray ក្រោមចំណងជើងថា *ការជៀសវាងពីអាការៈមិនស្មោះត្រង់៖ អំណាចបានមកជាមួយនឹងការទទួលខុសត្រូវ (Avoiding the Appearance of Impropriety: With Great Power Comes Great Responsibility)* ARK. LITTLE ROCK L. REV. 63, 65 (2005) ("Gray") ដែលពិភាក្សាអំពីក្រមសីលធម៌គំរូសម្រាប់ចៅក្រមរបស់គណៈមេធាវីអាមេរិចកាំង (American Bar Association Model Code of Judicial Conduct)។

[46] អង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Talić* នៅតុលាការ ICTY កត់សម្គាល់ថា ឧទាហរណ៍នៅ អ៊ីតាលី ចៅក្រមម្នាក់នឹងត្រូវដកគុណវុឌ្ឍិ នៅក្នុងកាលៈទេសៈនានាដែលនាំអោយបុគ្គលសមហេតុផលម្នាក់ចោទមានការសង្ស័យទៅលើភាពឥតលម្អៀងរបស់ខ្លួនដោយសារផលប្រយោជន៍ជាបុគ្គលផ្ទាល់ខ្លួន ឬហេតុផលដទៃទៀត។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Talić* សំណុំរឿង IT-99-36-PT សេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ Momir Talić ប្តឹងជំទាស់ចៅក្រម និងសុំដកចៅក្រមម្នាក់ ចុះថ្ងៃទី ១៨ ឧសភា ២000 កថាខណ្ឌ១៣ *យកជាសម្អាងនូវ* Codice di Procedura Penale មាត្រា៣៦ ។

[47] *សូមមើលផងដែរជាឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milošević* សំណុំរឿង IT-02-54-A-R77.4 សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំស្តីពី Kosta Bulatović មាក់ងាយតុលាការ ចុះថ្ងៃទី ២៩ សីហា ២00៥ កថាខណ្ឌ ១៧-១៨ ។

ភាពលំអៀង[48]។

៣២. លក្ខណៈវិនិច្ឆ័យនៅពេលនេះមិនមែនថា តើមានមនុស្សប៉ុន្មាននាក់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬភាគីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ ជូនជាសំណូកដល់ចៅក្រម និល ណុន ដើម្បីជាថ្នូរនឹងសេចក្ដីសម្រេច ដែលគួរជាទីពេញចិត្តនាពេលជំនុំជម្រះក្ដីនោះទេ។ មេធាវីការពារក្ដីសូមស្នើថា នេះគឺជាការយល់នេះមិនសមរម្យឡើយ ដោយគិតអំពីភាពស្អាតស្អំរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី[49]។ លក្ខណៈវិនិច្ឆ័យមិនមែនថា តើនៅក្នុងរឿងក្ដីនេះ ចៅក្រម និល ណុន ទំនងជាទទួលសំណូកនោះទេ ប៉ុន្តែថាតើនាអតីតកាល (ហើយដែលតាមរយៈការកត់សម្គាល់ដែលពាក់ព័ន្ធរបស់គាត់ វាហាក់ដូចជាទម្លាប់អនុវត្តដែលចេះតែបន្តទៅមុខទៀត) ដែលក្នុងករណីនោះ គាត់បានធ្វើខូចខាត និងបាត់បង់នូវភាពជាចៅក្រមស្អាតស្អំរបស់គាត់ដែរឬអត់។ តាមពិតទង្វើរបស់ចៅក្រម និល ណុន នឹងបណ្ដាលអោយអ្នកសង្កេតការណ៍ឥតលំអៀងម្នាក់ជឿថា សេចក្ដីសម្រេច និងសាលក្រមគឺសម្រាប់ដាក់លក់ ឬ បានសម្រេចសេចក្ដីដោយផ្អែកលើការពិចារណាក្រៅផ្លូវតុលាការ។

៣៣. បើទោះបីជា កំណត់សំគាល់ទាក់ទិនដល់ចៅក្រម និល ណុន ត្រូវបានគេមើលឃើញយ៉ាងច្បាស់ថាមានប្រយោជន៍មកដល់ខ្លួនគាត់ក៏ដោយ ការទទួលយក "សារគុណ" បន្ទាន់ពីរឿងក្ដីត្រូវបញ្ចប់ (ឬក៏សូម្បីតែមិនបញ្ចុះបញ្ចូលដើម្បីទទួលបានសារគុណនេះក៏ដោយ) គឺរំលោភបំពានច្បាប់កម្ពុជា និង

---

[48] យោងទៅតាមចៅក្រម Trechsel តុលាការ ICTY "[តុលាការសិទ្ធិមនុស្សអឺរុប] ជាញឹកញាប់និយាយថា "អាការៈខាងក្រៅគឺមានសារៈសំខាន់"។ ខ្ញុំនឹងមិនស្ទាក់ស្ទើនឹងឈានមួយជំហានបន្ថែមទៀត ហើយនិយាយថា នៅពេលដែលអនាគតិរបស់តុលាការត្រូវបានគេវាយតម្លៃ អាការៈខាងក្រៅគឺមិនមែនត្រឹមតែជាការបិទបាំង ឬ បង្ហាញមកក្រៅប៉ុណ្ណោះទេ។ អាការៈខាងក្រៅនោះឯងគឺជាបញ្ហា"។ អត្ថបទរបស់ STEPHAN TRECHSEL ក្រោមចំណងជើងថា សិទ្ធិមនុស្សក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ (HUMAN RIGHTS IN CRIMINAL PROCEEDINGS) ទំព័រ ៦៣ (Oxford University Press, 2005) ។

[49] ម្យ៉ាងវិញទៀត សូម្បីតែចៅក្រម និល ណុន មិនត្រូវបានគេសូកនៅក្នុងរឿងក្ដីបច្ចុប្បន្ននេះក៏ដោយ ការលំអៀងពិតប្រាកដក៏ដូចជាអាការៈលំអៀងអាចកើតមានឡើង។ នៅក្នុងរឿងក្ដី *Bracy v. Gramley* តុលាការកំពូលសហរដ្ឋអាមេរិច បានយល់ស្របជាមួយអ្នកដាក់បណ្ដឹងថា "ការលំអៀងដើម្បីប៉ះប៉ូវ (compensatory bias)" អាចកើតមានឡើងនៅពេលដែលចៅក្រមម្នាក់ មិនត្រូវបានគេសូក ឬបានទទួលសំណូកនៅក្នុងរឿងក្ដីមួយជាក់លាក់ក៏ដោយ បើសិនជាចៅក្រមនោះត្រូវបានគេបង្ហាញភស្តុតាងថាបានទទួលសំណូកនៅក្នុងរឿងក្ដីផ្សេងទៀត។ រឿងនេះអាចកើតមាននៅពេលដែលចៅក្រមម្នាក់យល់ឃើញប្រឆាំងនឹងចុងចោទនៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយ ដើម្បីជៀសវាងពីការត្រូវបានគេឃើញថាមានភាពទន់ភ្លន់ពេកមកលើចុងចោទក្នុងរឿងព្រហ្មទណ្ឌ ដើម្បីបិទបាំងនូវបញ្ហាដែលថា គាត់ត្រូវបានគេរកឃើញថាបានលំអៀងទៅចុងចោទដទៃទៀត ដែលបានសូកគាត់ ដើម្បីទទួលបានលទ្ធផលគួរទីពេញចិត្ត។ *សូមមើលផងដែរ* *Bracy v. Gramley*, 520 U.S. 899, 905, 909 (1997)។

ក្រមសីលធម៌តុលាការ និងបង្កើតបានជាភាពលំអៀង[50]។ មាត្រា ១ (ឯករាជ្យភាពនៃក្រុមចៅក្រម) និងមាត្រា ៣៨ (ការជំរិតទារប្រាក់/អំពើពុករលួយ) របស់ច្បាប់អ៊ិនតាក់ បាននៅជាធរមាននៅពេលដែលចៅក្រម និល ណុន បានឆ្លើយពីការទទួលស្គាល់របស់គាត់ទៅកាន់អ្នកនាង Pike នៅក្នុងឆ្នាំ ២០០២ និងនៅខណៈពេលសព្វថ្ងៃនេះ។ វាប្រហែលជាអាចទៅរួចដែរដែលពេលវេលាសមរម្យសម្រាប់ភាគីវិវាទមួយ ផ្តល់នូវសំណូក ឬ "សារគុណ" ទៅចៅក្រមម្នាក់ដើម្បីទទួលបាននូវលទ្ធផលទៅតាមបំណងរបស់ខ្លួន បន្ទាប់ពីរឿងក្តីត្រូវបានបញ្ចប់។ ហេតុអ្វីត្រូវប្រគល់ប្រាក់កាសនៅពេលដែលលទ្ធផលដែលម្នាក់ចង់បាន មិនទាន់ចេញជារូបរាងនោះ? គេប្រហែលជាអាចយល់បានដែរថា វាជាចងចៅក្រម ដោយហេតុថា សារគុណនឹងត្រូវបានគេផ្តល់ជូននៅពេលដែលលទ្ធផលបានសម្រេចគួរជាទីគាប់ចិត្ត ហើយការផ្តល់សារគុណនឹងធ្វើឡើងបន្ទាប់ពីទទួលបាននូវលទ្ធផលនោះ។ គេអាចយល់បានផងដែរថា សេចក្តីសម្រេចនឹងលំអៀងទៅភាគីដែលនឹង

[50] "អាការៈខាងក្រៅដែលចៅក្រមកំពុងព្យាយាម "ប្រមូលគុណបំណាច់ពីអតីតកាល" (collect for pas deeds) អាចកើតចេញពីសកម្មភាពនានាដែលធ្វើឡើងដោយចៅក្រមនោះ បន្ទាប់ពីសេចក្តីសម្រេចត្រូវបានធ្វើឡើង។ នៅក្នុងរឿងក្តី *Adam តទល់នឹង គណៈកម្មាធិការស្តីពីការប្រព្រឹត្តរបស់ចៅក្រម (Commission on Judicial Performance)* បន្ទាន់ពីបានប្រគល់ជ័យជំនះដល់អ្នកជំនួញរថយន្តចំនួន ៥លានដុល្លា នៅក្នុងរឿងក្តីរដ្ឋប្បវេណីដ៏ស្មុគស្មាញមួយប្រឆាំងនឹងធនាគារ ខណៈពេលដែលរឿងក្តីកំពុងរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ ចៅក្រមបានធ្វើពាណិជ្ជកម្មនានាមួយចំនួនជាមួយអ្នកជំនួញនោះ ឧទាហរណ៍ ការទិញរថយន្តម៉ែកសេដេសជជុះសម្រាប់ប្រពន្ធរបស់គាត់ និងរថយន្តហ្ស៊ីពជជុះសម្រាប់កូនស្រីរបស់គាត់។ នៅក្នុងអំឡុងពេលរឿងក្តីនៅចំពោះមុខចៅក្រម អ្នកជំនួញរថយន្តត្រូវបានតំណាងដោយមេធាវីការពារ Patrick Frega ហើយនៅក្នុងការធ្វើពាណិជ្ជកម្មមួយចំនួន ចៅក្រមនោះបានពឹង Frega ដែលជននេះ ដោយមិនបានដឹងដល់ចៅក្រម បានចាត់ចែងអោយចៅក្រមទទួលបានតម្លៃដ៏គួរអោយពេញចិត្តមួយ។ តុលាការកំពូលកាលីហ្វ័រញ៉ា បានសន្និដ្ឋានថា កំណត់ត្រាមិនបានបង្ហាញច្បាស់លាស់ ហើយភស្តុតាងដែលគួរអោយជឿបាន បង្ហាញថា ចៅក្រមមិនបានផ្តួចផ្តើមការធ្វើពាណិជ្ជកម្មនានាដោយ "មានការរំពឹងទុកជាមុនទទួលបាននូវផលប្រយោជន៍ហិរញ្ញវត្ថុ" ពីអ្នកជំនួញឡើយ។ ប៉ុន្តែ តុលាការបានរកឃើញថា ដោយស្នើសុំអោយមានជំនួយពីភាគីវិវាទម្នាក់ ដែលសម្រាប់ភាគីនោះចៅក្រមបានចេញសេចក្តីសម្រេចដែលតម្លៃជាប្រាក់ដ៏ក្រាស់ក្រែលនោះ ហើយដែលប្រយោជន៍របស់ភាគីនៅតែមាននៅចំពោះមុខចៅក្រមនោះ ចៅក្រមនេះ<u>បានបង្កើតអោយមានភាពមិនស្មោះត្រង់</u> (impropriety) ..."។ លើសពីនេះ ចៅក្រម Adam បានទទួលនូវអាវរងាដែលមានតម្លៃ ១៥០ដុល្លា ពីអ្នកជំនួញនោះនៅឆ្នាំដំណាលគ្នានឹងសាលក្រម ហើយបានចូលរួមពិសារអាហារពេលល្ងាច ដែលធ្វើឡើងដោយFrega ជាកិច្ចអបអរនូវសាលក្រមដែលគួរជាទីពេញចិត្ត ដែលចៅក្រមនោះបានឡើងកាត់សេចក្តីអោយនោះ។ តុលាការរកឃើញថា ថ្វីបើចៅក្រមមិនស្នើសុំនូវអំណោយនោះក្តី "នៅក្រោមកាលៈទេសៈនានា វាមានការចាំបាច់ចំពោះចៅក្រមនោះដែលត្រូវអោយវាទៅគេវិញ ... <u>ដើម្បីជៀសវាងមន្ទិលសង្ស័យផ្សេងៗទាក់ទងនឹងឯករាជ្យភាពរបស់ចៅក្រមនោះ ឬ អាការៈខាងក្រៅនៃភាពស្មោះត្រង់</u>" អត្ថបទរបស់ Gray នៅទំព័រ ៨០-៨១ (គូសបញ្ជាក់បន្ថែម) ។

00636117



ផ្តល់មុខជានឹងផ្តល់អ្វីមួយ។

៣៤. លោក រាជ សម្បត្តិ អតីតអ្នកនាំពាក្យ អវតក ហើយឥឡូវជាប្រធានអង្គភាពកិច្ចការសាធារណៈ បានថ្លែងថា បញ្ហានៃអំពើពុករលួយរបស់ចៅក្រម និល ណុន គឺមិនទាក់ទងទៀតទេ ក្រោយពេលដែលចៅក្រម និល ណុន "បានបដិសេធរឿងនោះរួចរាល់ហើយ ហើយរឿងនោះកើតឡើងយូរយារណាស់មកហើយ ... វាមិនមានឥទ្ធិពលដល់តុលាការនេះទេ។ កិច្ចការនេះគឺមិនធម្មតាទេ។ អ្វីៗគឺសុទ្ធតែថ្មីទាំងអស់" [51]។ លោក រាជ សម្បត្តិ ក៏បានថ្លែងផងដែរថា ចៅក្រមកម្ពុជាទាំងឡាយ "អាចមានឱកាសដើម្បីកសាងនូវកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើងវិញ" តាមរយៈកិច្ចការរបស់អ្នកទាំងនោះនៅ អវតក[52]។

៣៥. វាជារឿងអាក្រក់បំផុត ដែលអ្នកនាំពាក្យម្នាក់របស់ អវតក ប៉ុនប៉ងធ្វើអោយបញ្ហានេះលែងជារឿងសំខាន់។ ថ្វីបើ ចៅក្រមទាំងឡាយរបស់ អវតក ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ("ក្រុមប្រឹក្សាចៅក្រម")[53] មិនមែនដោយអង្គការសហប្រជាជាតិ UNAKRT គួរបានធ្វើការស៊ើបអង្កេតទៅលើបញ្ហានៃការទទួលយកសំណូករបស់ ចៅក្រម និល ណុន ហើយគួរបានស្នើអោយ ក្រុមប្រឹក្សាចៅក្រម តែងតាំងចៅក្រមម្នាក់ដែលឯករាជ្យ និងឥតលំអៀង ជំនួសចៅក្រម និល ណុន។ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ តម្រូវថា "ចៅក្រម<u>ត្រូវតែជា</u>បុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និង សុចរិត ...។ ចៅក្រម<u>ត្រូវ</u>ឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និង<u>មិនអាច</u>ទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ"[54]។

៣៦. បញ្ហាដែលថា ចៅក្រម និល ណុន បានបដិសេធដោយថ្លែងថា គាត់បានទទួលយកសំណូក គឺមិនមែនត្រូវបញ្ចប់រឿងនោះទេ។ ចៅក្រម និល ណុន ត្រូវបានគេរំពឹងជាខ្លាំងថាបានឆ្លើយទទួលស្គាល់ការទទួលយកសំណូក ឥឡូវនេះ តួនាទីរបស់គាត់នៅ អវតក អាចត្រូវបានគំរាមកំហែងដោយសារ

---

[51] អត្ថបទសរសេររបស់ James Welsh & Prak Chan Thul ក្រោមចំណងជើងថា *អ្នកផលិតខ្សែភាពយន្តបានឲ្យដឹងថា ចៅក្រមនៅ អវតក បានទទួលប្រាក់ពីប្រជាជន* CAMBODIA DAILY ១០-១១ មិថុនា ២00៦។

[52] អត្ថបទសរសេររបស់ James Welsh & Prak Chan Thul ក្រោមចំណងជើងថា *អ្នកនាំពាក្យសាលាក្តីខ្មែរ បាននិយាយថា ការកាត់ក្តីខ្មែរក្រហមនឹងផ្តល់ឱកាសអោយចៅក្រម និងព្រះរាជអាជ្ញាស្តារមុខមាត់របស់ពួកគាត់ឡើងវិញ* CAMBODIA DAILY ៥-៦ ឧសភា ២00៦។

[53] *សូមមើល* ច្បាប់បង្កើត អវតក មាត្រា ១១ថ្មី ។

[54] កិច្ចព្រមព្រៀង មាត្រា ៣ (គូសបញ្ជាក់បន្ថែម) ។

00636118



ការឆ្លើយទទួលស្គាល់បែបនេះ។ ការបដិសេធរបស់គាត់មិនអាចយកមកធ្វើការច្រានចោលការសម្តែងមកក្រៅនូវ ការមិនឯករាជ្យ និងមានភាពលំអៀង ដែលបានបង្កើតឡើងដោយសារការលាតត្រដាងនូវការទទួលយកសំណូករបស់គាត់បានឡើយ។

៣៧. លើសពីនេះទៀត វាមិនមានអ្វីជាបញ្ហាដែលថា តើចៅក្រម និល ណុន បានត្រឹមទទួលសំណូក "យូរយារណាស់មកហើយ" ឬថា តើគាត់នៅតែទទួលសំណូករហូតមកដល់សព្វថ្ងៃនេះនោះទេ។ ទង្វើអតីតកាលរបស់ចៅក្រម និល ណុន ដែលគេចោទប្រកាន់ គឺធ្ងន់ណាស់ និងចង្អុលបង្ហាញពីការប្រមាថចំពោះភាពចាំបាច់ចំពោះគុណភាពចៅក្រមដែលមានឯករាជ្យ អនាគតិ និងស្អាតស្អំ ដែលអ្នកសង្កេតការណ៍ឥតលំអៀងម្នាក់ នឹងលែងជឿថាចៅក្រម និល ណុន អាចអោយគេទុកចិត្តថា នឹងកាត់សេចក្តីរឿងក្តីលោក អៀង សារី ក្នុងរបៀបឯករាជ្យ និងមានអនាគតិនោះ។ បញ្ហាមិនមែនថា តើចៅក្រម និល ណុន មានភាពលំអៀងប្រឆាំងនឹងលោក អៀង សារី នោះ ទេ។ ហើយក៏មិនមែនជាចំណោទដែលថា តើគាត់ប្រហែលជាអាចប្រើប្រាស់នូវគំនិតឥតលំអៀង និងគ្មានបុរេវិនិច្ឆ័យទៅលើរឿងក្តី នៅចំពោះមុខគាត់ដែរឬអត់នោះឡើយ។ បញ្ហានោះគឺថា តើអ្នកសង្កេតការណ៍ដែលគេសន្មតថាមានគំនិតឥតល្អៀង ហើយទទួលបានព័ត៌មានគ្រប់គ្រាន់ នឹងយល់ឃើញថាចៅក្រម និល ណុន "ប្រហែលជាមិនអាចប្រើប្រាស់នូវគំនិតឥតលំអៀង និងគ្មានបុរេវិនិច្ឆ័យទៅលើរឿងក្តី នៅចំពោះមុខគាត់មែនឬក៏អត់" [55]។

## V. សេចក្តីសន្និដ្ឋាន និងសំណូមពរ

៣៨. អវតក មិនមែនជាកន្លែងមួយសម្រាប់ចៅក្រមម្នាក់ "កសាងនូវកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើងវិញនោះទេ"។ អង្គការសហប្រជាជាតិ បានអនុវត្តក្រមអ៊ិនតាក់នៅប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩២។ ក្រមនេះ ចែងជាពិសេសនូវការទទួលខុសត្រូវរបស់ចៅក្រមទាំងឡាយអោយមានឯករាជ្យ និងសម្រេចលើរឿងក្តីនានា "ដោយមានអនាគតិពេញលេញ[56]" ហើយក៏ហាមប្រាមបន្ថែមទៀតដល់ចៅក្រមទាំងឡាយ កុំអោយស្នើសុំ ទទួល ឬប៉ុនប៉ងទទួល "ទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់កាស បុគ្គលមុខងារ ឯកសារ សេចក្តីអនុញ្ញាត ឬ ផលប្រយោជន៍អ្វីមួយ" ជាថ្នូរនឹងការបំពេញករណីកិច្ចផ្លូវការ

[55] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* សំណុំរឿង IT-95-17/1-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២១ កក្កដា ២០០០ កថាខណ្ឌ ១៨៩ (គូសបញ្ជាក់បន្ថែម) ។

[56] ក្រមអ៊ិនតាក់ មាត្រា ១។

មួយឡើយ[57]។

៣៩. អវតក ត្រូវបានបង្កើតឡើងដោយមានជំនួយពីអន្តរជាតិ ដើម្បីធានាដំណើរការនីតិវិធីតុលាការមានយុត្តិធម៌តាមស្តង់ដារអន្តរជាតិ។ យោងទៅតាមគេហទំព័ររបស់ អវតក៖

> រាជរដ្ឋាភិបាលកម្ពុជា បានទទូចសុំថាដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ តុលាការជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់មន្ត្រី និងចៅក្រមកម្ពុជាគួបផ្សំជាមួយមន្ត្រី និងចៅក្រមអន្តរជាតិ។ កម្ពុជាបានអញ្ជើញសហគមន៍អន្តរជាតិ អោយចូលរួមសហការក្នុងកាត់សេចក្តីនេះ ដើម្បីធានាអោយមានយុត្តិធម៌ជាលក្ខណៈស្តង់ដារអន្តរជាតិ ព្រោះកម្ពុជាយល់ឃើញថា ខ្លួននៅទន់ខ្សោយផ្នែកតុលាការ និងចរិតលក្ខណៈអន្តរជាតិនៃឧក្រិដ្ឋកម្ម។ ចុងបញ្ចប់កិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិ ត្រូវបានចុះហត្ថលេខានៅខែមិថុនា ឆ្នាំ ២០០៣ ដែលចែងថា តើសហគមន៍អន្តរជាតិនឹងជួយឧបត្ថម្ភ និងសហការរបៀបដូចម្តេចនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ។ តុលាការថ្មីហើយពិសេសនេះ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ប៉ុន្តែតុលាការនេះ គឺឯករាជ្យម្ចាស់ការមិនចំណុះអោយរាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិទេ។ តុលាការនេះ គឺជាតុលាការកម្ពុជាដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ។ តុលាការនេះ នឹងផ្តល់ជាគំរូថ្មីមួយសំរាប់ដំណើរការកាត់ក្តីនៅកម្ពុជា។[58]

៤០. ចៅក្រមទាំងឡាយនៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើពាក្យបណ្តឹងជំទាស់នេះ ដាច់ខាតមិនត្រូវយោគយល់ ដោយសារភាពជាមិត្តរួមការងារមានវត្តមានជាមួយគ្នាជាចៅក្រមនៅក្នុងអង្គជំនុំជម្រះឡើយ ហើយមិនត្រូវយោគយល់ដោយសារឥទ្ធិពលនៃការដកគុណវុឌ្ឍិដែលអាចមានមកលើចៅក្រម និល ណុន ឡើយ។ វាគ្មានការពិចារណាណាដែលមានសុពលឡើយ នៅពេលដែលសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់សេចក្តីដោយតុលាការ ដែលឯករាជ្យ និងឥតលំអៀងកំពុងប្រឈមនឹងគ្រោះថ្នាក់នោះ[59]។ ហើយក៏មិនមែនដោយសារបញ្ហាដែលថាមេធាវីការពារក្តីក្នុង

---

[57] *ដូចយោងខាងលើ មាត្រា ៣៨។*

[58] *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://www.eccc.gov.kh/english/about_eccc.aspx. (គូសបញ្ជាក់បន្ថែម។)។

[59] មេធាវីការពារក្តី កត់សម្គាល់ថា សូម្បីតែបញ្ហាទាំងនេះ*ធ្លាប់*ជាការយល់ឃើញថាសុពលភាពក៏ដោយ គេមិនត្រូវអោយមានឥទ្ធិពលមកលើលទ្ធផលនៃពាក្យបណ្តឹងជំទាស់បច្ចុប្បន្ននេះឡើយ ដោយហេតុថា ការជំនុំជម្រះក្តីមិនទាន់បានចាប់ផ្តើមនៅឡើយ

00636120



សំណុំរឿង 00១ មិនបានធ្វើការប្តឹងជិតចិត្តនោះឡើយ។ រឿងនេះមិនអាចលុបលាងអ្វីដែលគេបានយល់ឃើញថាជាអាកប្បកិរិយាអាក្រក់ពីអតីតកាលរបស់គាត់បានឡើយ។ មេធាវីការពារក្តី *ខុច* ប្រហែលអាចមិនបានដឹងអំពីអំពើពីអតីតកាល ឬក៏ប្រហែលអាចមានហេតុផ្សេងទៀតក្នុងខកខានមិនបានលើកឡើងពីបញ្ហានេះ។ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែពិចារណាត្រឹមតែថា តើចៅក្រម និល ណុន "បាន ឬធ្លាប់បានមានទំនាក់ទំនង ដែលអាចបណ្តាលអោយប៉ះពាល់ដល់អនាគតិរបស់ខ្លួន ឬ អាចបណ្តាលអោយលេចចេញនូវភាពលំអៀង"[60]។

៤១. លទ្ធភាពក្នុងការសម្រេចលើពាក្យបណ្តឹងជិតចិត្ត ដោយសំអាងត្រឹមតែច្បាប់ដែលអាចយកមកអនុវត្ត គឺជា លក្ខណៈវិនិច្ឆ័យនៃឯករាជ្យភាព និងអនាគតិរបស់អង្គជំនុំជម្រះទាំងមូល ។ ការអនុញ្ញាតអោយចៅក្រមពុករលួយម្នាក់ នៅបន្តអង្គុយជំនុំជម្រះ ប៉ះពាល់ដល់ភាពស្អាតស្អំ និងកេរ្តិ៍ដំណែលរបស់ អវតក ។ សេចក្តីសម្រេចមួយទៅលើពាក្យបណ្តឹងជិតចិត្តបច្ចុប្បន្ននេះ អនុញ្ញាតអោយតុលាការមានឱកាសល្អដើម្បីចង្អុលបង្ហាញថា នីតិរដ្ឋដាច់ខាតត្រូវតែបានគេយកមកអនុវត្តនៅប្រទេសកម្ពុជា[61]។

**អាស្រ័យហេតុនេះ** ដោយមានហេតុផលទាំងអស់ដូចបានលើកឡើងនៅទីនេះ មេធាវីការពារក្តី សូមស្នើដល់ចៅក្រម និល ណុន **ដកខ្លួនថយ**ចេញពីគ្រប់នីតិវិធីទាំងអស់ និងការត្រៀមរៀបចំ រហូតលំពេលមានសេចក្តីសម្រេចទៅលើពាក្យបណ្តឹងជិតចិត្តនេះត្រូវបានធ្វើឡើង ហើយស្នើដល់អង្គជំនុំជម្រះសាលាដំបូងថា៖

ក. **ផ្តល់ជូនដល់** មេធាវីការពារក្តីនូវ**សវនាការសាធារណៈ**ស្តីពីបញ្ហានេះ ឬ ជាជម្រើសផ្សេងពីនេះ អនុញ្ញាតអោយដាក់**ចម្លើយតប**ទៅនឹងអំណះអំណាងនានាដែលបានដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្តឹងជិតចិត្តនេះ

ខ. **ពិចារណា** លើសំណើសុំស៊ើបអង្កេតស្របពេលជាមួយគ្នានឹងពាក្យបណ្តឹងជិតចិត្តនេះ និង

---

ហើយចៅក្រម និល ណុន មិនបានចំណាយពេលវេលា និងថាមពលទៅលើរឿងក្តីនេះឡើយ ហើយក៏មិនទាន់បានធ្វើការជិតស្និទជាមួយសហសេវិកទាំងឡាយរបស់គាត់ទៅលើរឿងក្តីនេះនៅឡើយ។

[60] វិធាន ៣៤(២)។

[61] "ចាប់តាំងពីដើមដំបូង អង្គការសហប្រជាជាតិធ្លាប់បានខ្វាយខ្វល់អំពីការរីករាលដាលនៃអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការជាតិកម្ពុជា ក៏ដូចជាកង្វះសមត្ថភាព និងប្រវត្តិនៃវិស័យយុត្តិធម៌ដែលលាយឡំនឹងនយោបាយ នឹងរារាំងតុលាការនេះមិនអោយមានយុត្តិធម៌តាមស្តង់ដាអន្តរជាតិ" របាយការណ៍របស់ OSJI ទំព័រ ២។

០០២/19-09-2007-អវតក/សចស

~~00២/១៣-០១-២០១១/អ.វ.ត.ក/អជសអ~~

ES

គ. **សុំដក** ចៅក្រម និល ណុន អនុលោមទៅតាមវិធាន ៣៤(២)។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកពាក្យបណ្តឹងជំទាស់នេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**